# ដំណឹងល្អរបស់ព្រះយេស៊ូវ



## ការលះបង់ និង សេចក្តីអំណរ

## នៃការក្លាយជាកូនព្រះ


និពន្ធដោយ :

លោក មិច្ឆែល ហ្វោរេស្ទ នៅខេត្តពោធិ៍សាត់  ០១២ ៦០ ៥៩ ៧១

និង

លោក ស៊ីរ៉ែត គ្រីស នៅខេត្តប៉ៃលិន ០១២ ៧៩ ២៥ ២៩

# សេចក្តីផ្តើមនៃកូនសៀវភៅ*ដំណឹងល្អរបស់ព្រះយេស៊ូវ*

គោលបំណងកូនសៀវភៅនេះគឺ ជួយឱ្យអ្នកមានចិត្តចង់ជឿលើព្រះយេស៊ូវ បានយល់ច្បាស់ពីអត្ថន័យនៃការទទួលជឿលើព្រះយេស៊ូវ ។ សេចក្តីជំនឿជឿលើព្រះយេស៊ូវ ដើម្បីឱ្យបានសេចក្តីសង្គ្រោះ គឺជាការសំរេចចិត្តមួយដែលមានសារៈសំខាន់ជាងគេបំផុត ។ ហើយវាក៏ជាការសំរេចចិត្ត ដែលនាំមកនូវការផ្លាស់ប្តូរនៅក្នុងជីវិត ។ ដូច្នេះ ការសំរេចចិត្តនេះ វាមិនមែនចេះតែធ្វើទៅដោយមិនបានដឹងច្បាស់ថា ខ្លួននឹងត្រូវធ្វើអ្វីបន្ទាប់ពីនោះឡើយ ។

ព្រះអម្ចាស់យេស៊ូវគ្រីស្ទមានបន្ទូលថា នៅថ្ងៃជំនុំជំរះរបស់មនុស្សលោក ថ្ងៃនោះនឹងមានមនុស្សជាច្រើន ដែលនឹងមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ហើយងឿងឆ្ងល់ថា ហេតុអ្វីបានជាព្រះអង្គមិនទទួលស្គាល់ពួកគេ ហើយបោះពួកគេចោលទៅក្នុងឋាននរក ។ តើហេតុអ្វីបានជាទៅដូច្នេះ ? សូមអាន ម៉ាថាយ ៧:២១-២៣ មានមនុស្សជាច្រើនដែលស្មានថា ខ្លួនជឿលើព្រះយេស៊ូវហើយ ខ្លួនជាអ្នកគ្រីស្ទានហើយ ក៏ប៉ុន្តែពួកគាត់មិនមែនជាកូនរបស់ព្រះអង្គពិតនោះទេ ។ អ្នកខ្លះបញ្ឆោតខ្លួនឯងដោយរាប់ខ្លួនឯងថា ជាអ្នកជឿ ដោយសារខ្លួនធ្លាប់ចូលរួមថ្វាយបង្គំព្រះយេស៊ូវ ហើយក៏បានទទួលពិធីជ្រមុជទឹក ព្រមទាំងជូនកាលថ្វាយដង្វាយដល់ទ្រង់ផងដែរ ។ អ្នកផ្សេងទៀត គេស្មានថា ខ្លួនឯងក្លាយជាគ្រីស្ទបរិស័ទហើយ ពីព្រោះពួកគេលែងថ្វាយបង្គំរូបព្រះ ឈប់សែន ហើយលែងអុជធូបថ្វាយព្រះដទៃ ។ អ្នកខ្លះបានចុះទៅផ្សាយដំណឹងល្អ ហើយជួយបង្រៀនគេទៀត ប៉ុន្តែនៅតែមិនទាន់ក្លាយជាកូនព្រះយេស៊ូវពិតនៅឡើយ ។ ពួកគេស្មានថា ខ្លួនគេជាកូនរបស់ព្រះ ដោយសារគាត់បានប្រព្រឹត្តតាមការទាំងអស់នោះ ប៉ុន្តែនៅថ្ងៃជំនុំជំរះនៃព្រះមកដល់ គេនឹងភ្ញាក់ខ្លួនថា គេមិនរួចពីទោសនៃអំពើបាបខ្លួនទេ ហើយក៏មិនមានសេចក្តីសង្គ្រោះពីព្រះយេស៊ូវដែរ ។

គោលបំណងរបស់កូនសៀវភៅនេះគឺ ជួយអ្នកឱ្យយល់ច្បាស់អំពីសេចក្តីសង្គ្រោះនៅក្នុងព្រះយេស៊ូវ ។ វាមានសារៈសំខាន់ណាស់ក្នុងការជួយអ្នកឱ្យយល់អំពីមូលហេតុត្រឹមត្រូវ ដែលគួរតែនាំចិត្តរបស់អ្នក មកជឿលើព្រះ ។ អ្នកត្រូវរៀនព្រះបន្ទូលនៃព្រះ មិនមែនពាក្យ ឬ គំនិតរបស់មនុស្សនោះឡើយ ។ គោលបំណងរបស់កូនសៀវភៅនេះគឺ នាំឱ្យអ្នកយល់នូវអត្ថន័យនៃដំណឹងល្អរបស់ព្រះគ្រីស្ទ ។

អ្នកជឿលើព្រះយេស៊ូវខ្លះឧស្សាហ៍ នាំអ្នកដទៃឱ្យជឿលើព្រះយេស៊ូវដូចគេដែរ ។ ការឧស្សាហ៍នេះល្អណាស់ ប៉ុន្តែភាពឧស្សាហ៍ព្យាយាមរបស់គេមិនបានប្រកាសប្រាប់ដំណឹងល្អទាំងស្រុងនោះទេ គឺគេបានកែផ្លាស់ដំណឹងល្អមួយចំនួន ដែលមាននៅក្នុងព្រះគម្ពីរ ។ នោះក៏ដោយសារតែគេចង់ឱ្យមនុស្សដែលមិនជឿលើព្រះអង្គ

ចាប់អារម្មណ៍ចង់ស្តាប់ចំពោះដំណឹងល្អនោះ ប៉ុន្តែដំណឹងល្អដែលគេបានផ្លាស់ប្តូរនោះ មិនមាននៅក្នុងព្រះគម្ពីរនោះទេ ។ តើអ្នកយល់ច្បាស់ឬទេ ? តើដំណឹងល្អនៃព្រះគ្រីស្ទគឺជាអ្វី ? តើអ្នកយល់អំពីមូលហេតុដែលអ្នកមិនទាន់ទទួលជឿលើព្រះយេស៊ូវដែរឬទេ? តើអ្នកដឹងទេថា ការសំរេចចិត្តជឿលើព្រះយេស៊ូវមានន័យដូចម្តេចខ្លះ ? មេរៀនទាំងអស់ក្នុងកូនសៀវភៅនេះ មានចំលើយសំរាប់សំណួរទាំងនេះ ។

យើងគិតថា ប្រហែលជាអ្នកធ្លាប់រៀនអំពីព្រះដ៏ពិត ដែលបានបង្កើតផ្ទៃមេឃ ផែនដី និងរបស់សព្វសារពើនោះរួចហើយ ។ បើសិនជាអ្នកមិនទាន់ដឹងអំពីរបៀបដែលទ្រង់បានបង្កើតលោកិយនេះទេ សូមទៅរកព្រះគម្ពីរព្រះយេស៊ូវមួយក្បាល ហើយអានព្រះគម្ពីរទាំងនេះគឺ : លោកុប្បត្តិ ជំពូក១-២ កិច្ចការ ១៧:២៤-៣១ និង អេសាយ ៤៥:២០-២៤ ។ ព្រះគម្ពីរទាំងអស់នោះនឹងពន្យល់ឱ្យយើងដឹងថា ព្រះជានរណា ។

កូនសៀវភៅនេះស្មានជាមុនទៀតថា អ្នកធ្លាប់រៀនអំពីប្រវត្តិមនុស្សលោកដំបូង ជាពិសេសនៅពេលដែលជីដូនជីតារបស់យើងនៅសម័យដើមបានប្រព្រឹត្តបាប ហើយវង្វេងពីព្រះ ។ លទ្ធផលនៃអំពើបាបរបស់លោកទាំងនោះ គឺបាននាំឱ្យមានសេចក្តីស្លាប់ និង ការរងទុក្ខវេទនា ចូលមកក្នុងលោកិយនេះ ។ បើសិនជាអ្នកមិនទាន់សិក្សាព្រះគម្ពីរទេ នោះសូមអ្នកបើកមើលព្រះគម្ពីរទាំងនេះគឺ : លោកុប្បត្តិ ជំពូក៣ ហើយ រ៉ូម ១:១៨-៣២ ។ ព្រះគម្ពីរទាំងអស់នោះនឹងពន្យល់ឱ្យយើងដឹងថា មនុស្សជានរណា ។

ម្យ៉ាងវិញទៀត កូនសៀវភៅនេះស្មានជាមុនទៀតថា អ្នករៀនរួចហើយអំពីការសន្យារបស់ព្រះចំពោះមនុស្សលោកនៅសម័យដើមថា មានថ្ងៃមួយ ព្រះនឹងចាត់ព្រះអង្គសង្គ្រោះយាងមកដើម្បីរំដោះមនុស្សលោក ឱ្យរួចផុតពីទោសនៃអំពើបាប ហើយទទួលយកជីវិតអស់កល្បរបស់ព្រះវិញ ។ ព្រះរាជបុត្រានៃព្រះបានបន្ទាប ព្រះអង្គទ្រង់ ហើយយាងមកពីឋានសួគ៌ ព្រមទាំងយកនិស្ស័យជាមនុស្សដើម្បីបំពេញការងារទាំងអស់នោះ ។ ព្រះយេស៊ូវគឺជាព្រះរាជបុត្រានោះឯង ។ ទ្រង់បានប្រព្រឹត្តតាមក្រិត្យវិន័យរបស់ព្រះជំនួសយើង ហើយព្រះអង្គ បានសងថ្លៃលោះបាបរបស់យើងផងដែរ ។ បើអ្នកមិនដែលរៀនអំពីការលះបង់របស់ព្រះយេស៊ូវនោះទេ សូមអានព្រះគម្ពីរទាំងនេះសិនគឺ : យ៉ូហាន ៣:១៦-១៨ ម៉ាកុស ជំពូក១៤-១៦ និង ពេត្រុសទី១ ២:២១-២៥ ។ ព្រះគម្ពីរទាំងអស់នោះនឹងពន្យល់ឱ្យយើងដឹងថា ព្រះយេស៊ូជានរណា ។

បើសិនជាអ្នកបានរៀនខ្លះអំពីកាលដើមដំបូងរបស់លោកិយ និងអំពីព្រះយេស៊ូវខ្លះហើយ កូនសៀវភៅនេះនឹងអាចជួយអ្នកបានច្រើន ។ ប្រហែលជាមានអ្នកខ្លះដែលត្រូវការជំនួយក្នុងការស្វែងយល់អំពី ព្រះជានរណា មនុស្សជានរណា ហើយព្រះយេស៊ូវជានរណា នោះមានសៀវភៅមួយដ៏ល្អដែលអាចជួយអ្នកឱ្យឆាប់យល់គឺ សៀវភៅ *សង់លើគ្រឹះមាំ* ។ អ្នកអាចរកទិញសៀវភៅនេះបាននៅគ្រប់ទីកន្លែង

ដែលមានលក់សៀវភៅអំពីព្រះយេស៊ូវ នៅទីក្រុងភ្នំពេញ ដូចជាបណ្ណាគារគ្រួសារ នៅផ្លូវលេខ២១៥ សង្កាត់ផ្សារដេប៉ូ ជាដើម ។

សូមអរគុណ !

# មេរៀនទី១--ហេតុអ្វីបានជាយើងត្រូវតែជឿលើព្រះយេស៊ូវគ្រីស្ទ?

## ផ្នែកទី១: ការរួចពីបាប

សាវ័កប៉ុលគឺជាអ្នកផ្សព្វផ្សាយដំណឹងល្អដែលមានបេសកកម្មសំខាន់មួយគឺ នាំមនុស្សនៅគ្រប់ទាំងស្រុកឱ្យជឿលើព្រះយេស៊ូវ ។ មុនពេលគាត់ជឿលើព្រះយេស៊ូវ គាត់ជាអ្នកដឹកនាំសាសនាម្នាក់ឈ្មោះសូល ដែលមានការលះបង់យ៉ាងខ្លាំងចំពោះសាសនារបស់គាត់ ។ គាត់ស្អប់ពួកគ្រីស្ទាន ជាអ្នកជឿលើព្រះយេស៊ូវ ហើយវាយដំពួកគេ ព្រមទាំងចាប់ដាក់គុក និងសម្លាប់ពួកគេខ្លះទៀតផង ។ ថ្ងៃមួយ នៅពេលដែលគាត់កំពុងតែធ្វើដំណើរទៅទីក្រុងមួយ ដើម្បីបៀតបៀនអ្នកជឿព្រះអង្គនៅទីនោះ ព្រះយេស៊ូវបានបើកសំដែងអង្គទ្រង់ឱ្យគាត់បានឃើញ ។ សូលក៏បានប្រែចិត្តពីអំពើបាបរបស់គាត់ ហើយបានទទួលជឿលើព្រះយេស៊ូវវិញ ។ ព្រះយេស៊ូវដែលបានសុគត ហើយមានព្រះជន្មរស់ឡើងវិញ បានប្រាប់សូលឱ្យប្រកាសដំណឹងល្អទៅដល់ជាតិសាសន៍ទាំងឡាយ ហើយថា គាត់នឹងមានការឈឺចាប់ជាច្រើនដោយសារតែដំណឹងល្អនេះ ។ នៅពេលនោះសូលបានដាក់ឈ្មោះថ្មីគឺ ប៉ុល ។ បើសិនជាអ្នកចង់អានអំពីទីបន្ទាល់របស់លោកប៉ុល នោះសូមអាន កិច្ចការ ៩:១-៣១ ។

ព្រះគម្ពីរ កិច្ចការ ជំពូក២៦ បង្រៀនយើងអំពីប្រវត្តិនៃបេសកកម្មរបស់សាវ័កប៉ុលថែមទៀត ។ នៅក្នុងពេលនោះ សាវ័កប៉ុលមានវ័យចាស់ហើយ ។ លោកបានផ្សាយដំណឹងល្អ ហើយនាំគេជឿលើព្រះយេស៊ូវច្រើននៅតាមស្រុកផ្សេងៗ ។ សាវ័កប៉ុលបានត្រូវអ្នកដឹកនាំសាសនានៅក្រុងយេរូសាឡឹមចាប់លោក ហើយរកឱកាសសម្លាប់គាត់ចោល ។ អ្នកដឹកនាំសាសនានោះបាននាំប៉ុលទៅឯស្តេចអ័គ្រីប៉ា ពីព្រោះពួកគេសង្ឃឹមថា ព្រះអង្គនឹងប្រកាសដាក់ទោសដល់សាវ័កប៉ុល ។ ឥឡូវលោកត្រូវធ្វើទីបន្ទាល់ឱ្យស្តេចអ័គ្រីប៉ាស្តាប់ ។ ក្នុងទីបន្ទាល់នោះ ប៉ុលបានប្រាប់ព្រះអង្គយ៉ាងច្បាស់អំពីរបៀបដែលព្រះយេស៊ូវបង្គាប់ឱ្យលោកបំពេញបេសកកម្ម ជាអ្នកផ្សាយដំណឹងល្អ។

<u>សូមអាន កិច្ចការ ២៦:១៦-១៨</u>

ចូរក្រោកឈរឡើង ដ្បិតខ្ញុំបានលេចមកឱ្យអ្នកឃើញ ដើម្បីនឹងតាំងអ្នកឱ្យធ្វើជាអ្នកបំរើ ហើយជាទីបន្ទាល់ពីអស់ទាំងការ ដែលអ្នកបានឃើញហើយ ព្រមទាំងការដែលខ្ញុំនឹងលេចមក ឱ្យអ្នកឃើញទៅមុខទៀត

ខ្ញុំបានញែកអ្នកចេញពីបណ្ដាជន និងពីពួកសាសន៍ដទៃ ដើម្បីនឹងចាត់អ្នកឱ្យទៅឯគេវិញ ប្រយោជន៍នឹងបំភ្លឺភ្នែកគេ ឱ្យបានបែរចេញពីសេចក្ដីងងឹត មកឯពន្លឺ ហើយពីអំណាចអារក្សសាតាំង មកឯព្រះវិញ ដើម្បីឱ្យគេបានរួចពីបាប ហើយបានទទួលមរដក ជាមួយនឹងពួកអ្នកដែលបានញែកជាបរិសុទ្ធ ដោយសារសេចក្ដីជំនឿជឿដល់ខ្ញុំ ។

នៅក្នុងខទាំងនេះព្រះយេស៊ូវប្រាប់អំពីមូលហេតុដែលគាត់ត្រូវតែប្រកាសដំណឹងល្អនេះទៅដល់មនុស្សទាំងអស់ ។ ខទាំងនេះប្រាប់យើងអំពីមូលហេតុត្រឹមត្រូវដែលយើងត្រូវតែជឿលើព្រះយេស៊ូវ ។ មានមនុស្សជាច្រើនដែលអះអាងថា ខ្លួនជឿលើព្រះគ្រីស្ទ ប៉ុន្តែមិនយល់ដំណឹងល្អនេះទេ ។ មនុស្សជាច្រើនចូលជាសមាជិកនៃក្រុមជំនុំដើម្បីទទួលផលប្រយោជន៍ពីអង្គការ  អ្នកខ្លះចង់មានការងារធ្វើ  អ្នកខ្លះសង្ឃឹមថា នឹងទទួលបានប្រាក់ខែ ទទួលបានជ្រូកយកទៅចិញ្ចឹម  អណ្ដូងទឹក ឬផលប្រយោជន៍ជាសម្ភារៈផ្សេងៗទៀត ។ ការមានជំនឿលើព្រះយេស៊ូវបែបដូចនេះ វាមិនមែនជាជំនឿពិតប្រាកដនោះទេ ។

អ្នកខ្លះទៀតប្រកាសថា គេជឿលើព្រះគ្រីស្ទ ព្រោះពួកគេគិតថា វិធីរបស់ពួកគ្រីស្ទានគឺជាវិធីដ៏ល្អ ។ ពួកគេគិតថា វាជាវិធីមួយដែលប្រសើរជាងវិធីផ្សេងៗទៀត  ហេតុដូច្នេះហើយបានជាពួកគេក៏ចង់ដើរតាមដែរ ។ អ្នកខ្លះមើលឃើញថា ប្រទេសមួយចំនួន ដែលមានពួកគ្រីស្ទាន គឺជាអ្នកមាន ដូច្នេះពួកគេគិតថា ការជឿលើព្រះយេស៊ូវនឹងធ្វើឱ្យជីវភាពរបស់គេកាន់តែប្រសើរឡើងមួយកំរិតទៀត ។ បើជឿលើព្រះគ្រីស្ទ ដោយសារហេតុផលទាំងនេះ នោះបង្ហាញឱ្យឃើញថា ពួកគេមិនយល់ពីដំណឹងល្អនៃព្រះគ្រីស្ទទេ ។ <u>គ្មាននរណាម្នាក់ដែលមកឯព្រះយេស៊ូវដោយមូលហេតុទាំងអស់នេះ ឱ្យបានក្លាយជាពួកគ្រីស្ទានដ៏ពិតប្រាកដនោះឡើយ ។  ដូច្នេះតើហេតុអ្វីបានជាយើងត្រូវតែជឿលើព្រះយេស៊ូវ ?</u>

សូមនឹកចាំដល់ជីដូនជីតាដំបូងរបស់យើងគឺ អ័ដាម និង អេវ៉ាដែលបានជ្រើសរើសធ្វើអំពើបាប ។ ការប្រព្រឹត្តអំពើបាបរបស់ពួកគេបាននាំមកនូវអំពើបាប ការឈឺចាប់ និងសេចក្ដីស្លាប់ ចូលមកក្នុងលោកិយនេះ ។ ពួកយើងទាំងអស់គ្នាមានបាប ហើយបានប្រឆាំងនឹងបញ្ញត្តិព្រះ ដូចជាជីដូនជីតាយើងទាំងនោះដែរ ហើយយើងសមនឹងទទួលបាននូវការដាច់ចេញពីព្រះ សេចក្ដីស្លាប់ និងទណ្ឌកម្មដ៏អស់កល្បជានិច្ច ។ ព្រះគម្ពីរពន្យល់យ៉ាងច្បាស់ថា អស់អ្នកដែលប្រព្រឹត្តអំពើបាប នោះមិនមែនជាកូនព្រះទេ គឺជាកូនរបស់សាតាំងដែលជាមេអារក្សទៅវិញទេ ។ ដោយសារអំពើបាបនោះ យើងទាំងអស់គ្នាស្ថិតនៅក្រោមអំណាចរបស់វា ។ អ្នកមានបាបទាំងអស់ត្រូវបានដាក់ទោសទៅក្នុងបឹងភ្លើងអស់កល្បជានិច្ចផងដែរ ។ ទោះបីជាមនុស្សជាច្រើនបានបង្កើតផ្លូវផ្សេងៗតាមរយៈសាសនា និងបុណ្យផ្សេងៗក៏ដោយ ពួកគេនៅតែស្ថិតនៅក្នុងសេចក្ដីងងឹត

ខាងឯវិញ្ញាណ និងអំណាចរបស់អារក្សសាតាំងដដែល ។ ព្រះយេស៊ូវមានបន្ទូលទៅសាវ៉ីកប៉ុលនៅក្នុងខទាំងនេះថា ចូរឱ្យគាត់ចេញទៅប្រាប់ប្រជាជនទាំងឡាយពីដំណឹងល្អ ដើម្បីជួយបំភ្លឺភ្នែកពួកគេ ឱ្យត្រឡប់ចេញពីសេចក្តីងងឹតខាងឯវិញ្ញាណ ទៅក្នុងពន្លឺខាងឯវិញ្ញាណវិញ ។ ព្រះយេស៊ូវប្រាប់ប៉ុលឱ្យបង្ហាញប្រាប់ប្រជាជនអំពីរបៀបចូលទៅក្នុងនគរនៃព្រះ ដើម្បីកុំឱ្យពួកគេស្ថិតនៅក្រោមការគ្រប់គ្រងរបស់អារក្សសាតាំងទៀត ។

បើប្រជាជនជឿលើដំណឹងល្អ និងចាកចេញពីសេចក្តីងងឹតទៅរកពន្លឺនៃព្រះវិញ តើពួកគេនឹងទទួលបានអ្វី ? តើព្រះយេស៊ូវបានសន្យាអ្វីខ្លះ ? តើហេតុអ្វីយើងគួរតែចេញពីនគររបស់អារក្ស ហើយចូលនគររបស់ព្រះយេស៊ូវទៅវិញ ?

<u>សូមអាន កិច្ចការ ២៦:១៨ ម្តងទៀត</u>

ប្រយោជន៍នឹងបំភ្លឺភ្នែកគេ ឱ្យបានបែរចេញពីសេចក្តីងងឹត មកឯពន្លឺ ហើយពីអំណាចអារក្សសាតាំង មកឯព្រះវិញ ដើម្បីឱ្យគេបានរួចពីបាប ហើយបានទទួលមរដក ជាមួយនឹងពួកអ្នកដែលបានញែកជាបរិសុទ្ធ ដោយសារសេចក្តីជំនឿជឿដល់ខ្ញុំ ។

ខនេះប្រាប់យើងថា មនុស្សទាំងអស់ដែលពិតជាជឿលើព្រះយេស៊ូវគ្រីស្ទនឹងទទួលបានប្រយោជន៍ពីរយ៉ាងគឺ <u>រួចពីបាប</u> និង <u>ទទួលមរតក</u> ។ យើងនឹងពន្យល់ការសន្យាទី១នៅក្នុងមេរៀននេះ ហើយនឹងពន្យល់ការសន្យាទី២នៅក្នុងមេរៀនទី២ ។

# ១. សេចក្តីសន្យាទី១: ការរួចពីបាប

## ក. តើហេតុអ្វីយើងត្រូវការរួចពីបាប ?

យើងបានប្រព្រឹត្តអំពើបាបជាច្រើនទាស់នឹងព្រះដែលបានបង្កើតយើងមក ។ យើងបានគោរពប្រតិបត្តិព្រះក្លែងក្លាយ យើងបានគោរព ព្រមទាំងបានធ្វើរូបចំលាក់ ដែលបានធ្វើឱ្យព្រះអម្ចាស់ដ៏ពិតទ្រង់មិនសព្វព្រះទ័យ ។ អំពើបាបផ្សេងទៀតដែលយើងបានប្រព្រឹត្តគឺ ការភូតកុហក ការប្រព្រឹត្តសាហាយស្មន់ ការមិនគោរពប្រតិបត្តិឪពុកម្តាយ ការលួចរបស់របរអ្នកដទៃ ការលោភចង់បានទ្រព្យសម្បត្តិអ្នកដទៃ ។ល ។ ស្ទើរតែគ្រប់ពេលវេលា យើងពុំបានស្រលាញ់ព្រះដោយអស់ពីដួងចិត្តរបស់យើងនោះទេ ហើយក៏ពុំបានស្រលាញ់អ្នកដទៃដូចជាខ្លួនយើងដែរ ។ អំពើបាបរបស់យើងច្រើនក្រៃលែង ឯដួងចិត្តយើងក៏ពេញដោយសេចក្តីអាក្រក់ដែរ ។ ដោយព្រោះព្រះទ្រង់បរិសុទ្ធ ទ្រង់មិនអាចបំភ្លេចនូវអំពើបាបរបស់យើងបានឡើយ ។ រាល់អំពើបាបរបស់យើងត្រូវតែមានការសងថ្លៃ ។ បើយើងសងថ្លៃ

នូវរាល់អំពើបាបរបស់យើង នោះយើងនឹងត្រូវសងថ្លៃរហូតនៅក្នុងបឹងភ្លើង ដ្បិតអំពើបាបរបស់យើង អាក្រក់ហួសប្រមាណនឹងអាចសងរួច ។ យើងមិនអាចសងថ្លៃលោះបាបទាំងអស់របស់យើងបានទេ ទោះក្នុងរយៈពេលមួយឆ្នាំ ១០០ឆ្នាំ ឬ ក៏មួយលានឆ្នាំក៏ដោយ ។ អស់អ្នកទាំងឡាយណាដែលធ្លាក់ចូលទៅក្នុងឋាននរកមិនអាចចេញមកវិញបានទេ ពីព្រោះតែគ្មាននរណាម្នាក់អាចសងថ្លៃលោះបាបរបស់ពួកគេបានឡើយ គឺគេត្រូវរងទុក្ខដ៏នៅអស់កល្បជានិច្ចក្នុងឋាននរក ។

<u>សូមអាន វិវរណៈ ២១:៨</u>

តែត្រង់ពួកខ្លាច ពួកមិនជឿ ពួកគួរខ្ពើម ពួកកាប់សំឡាប់គេ ពួកកំផិត ពួកមន្តអាគម ពួកថ្វាយបង្គំរូបព្រះ ហើយគ្រប់ទាំងមនុស្សកំភូត គេនឹងមានចំណែកនៅក្នុងបឹងដែលឆេះជាភ្លើងនិងស្ពាន់ធ័រ គឺជាសេចក្តីស្លាប់ទី២វិញ ។

<u>សូមអាន ម៉ាថាយ ២៥:៤៦</u>

ឯពួកអ្នកទាំងនោះនឹងថយទៅ មានទោសអស់កល្បជានិច្ច តែពួកសុចរិតនឹងចូលទៅ ក្នុងជីវិតដ៏នៅអស់កល្បជានិច្ចវិញ ។

បើសិនជាអ្នកខំប្រឹងដើរតាមផ្លូវសុចរិតរបស់ខ្លួនឯង ឬរបស់សាសនា នោះតែងតែខ្វះមិនដល់សិរីល្អនៃព្រះ ។ ដើម្បីសុចរិតដោយការប្រព្រឹត្ត អ្នកត្រូវកាន់តាមក្រិត្យវិន័យរបស់ព្រះទាំងមូលពេញមួយជីវិត ហើយកើតមកពីមាតាបិតា ដែលគ្មានអំពើបាបដែរ ។ យើងមិនអាចធ្វើបុណ្យណាដើម្បីក្លាយជាស្អាតនៅចំពោះព្រះបានឡើយ ។ ផ្លូវសាសនាជួយយើងក៏មិនបានដែរ ។ ដូច្នេះយើងត្រូវធ្វើដូចម្តេច ដើម្បីរួចពីអំពើបាបរបស់យើង ហើយទទួលជីវិតរបស់ព្រះយ៉ាងម៉េចបាន ?

## ខ. តើនរណាអាចសងថ្លៃលោះបាបរបស់យើងបាន ?

ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ បានយាងមកពីឋានសួគ៌ មកគង់នៅលើផែនដី ហើយចាប់កំណើតជាមនុស្ស ដើម្បីឱ្យមនុស្សទាំងអស់អាចរួចពីបាបបាន ។ ទ្រង់បានបំពេញគ្រប់ទាំងក្រិត្យវិន័យនៃព្រះសំរាប់យើងគ្រប់ៗគ្នា ។ ទ្រង់ពុំធ្លាប់ប្រព្រឹត្តអំពើបាបណាមួយសោះឡើយ ។ ទ្រង់មិនសមនឹងបានទទួលរងនូវការធ្វើគត់ឡើយ តែទ្រង់ជ្រើសរើសយកការលះបង់ជីវិតសំរាប់យើងរាល់គ្នា ។ ទ្រង់ទទួលយកនូវរាល់អំពើបាបរបស់យើងទាំងអស់ ដាក់លើរូបអង្គទ្រង់ នៅលើឈើឆ្កាង និងទទួលនូវបទពិសោធនៃការឈឺចាប់ដ៏លើសលប់សំរាប់អង្គទ្រង់ ទាំងរូបកាយ

ទាំងវិញ្ញាណជំនួសយើងគ្រប់ៗគ្នា ។ ទ្រង់បានសងថ្លៃលោះបាបទាំងឡាយដែលយើងបានប្រព្រឹត្ត ។ សេចក្តីក្រោធនៃព្រះចំពោះអំពើបាបរបស់យើង បានចាក់ស្រោចមកលើទ្រង់ ។

សូមអាន អេសាយ ៥៣:៥-៦

តែទ្រង់ត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើង ក៏ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតរបស់យើងទេ ឯការវាយផ្ចាល ដែលនាំឱ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឱ្យជា ដោយសារស្នាមរំពាត់នៅអង្គទ្រង់ យើងទាំងអស់គ្នាបានទាស់ចេញដូចជាចៀម គឺយើងបានបែរចេញទៅតាមផ្លូវយើងរៀងខ្លួន ហើយព្រះយេហូវ៉ាបានទំលាក់អំពើទុច្ចរិតរបស់យើងទាំងអស់គ្នាទៅលើទ្រង់ ។

ខគម្ពីរទាំងនេះប្រាប់យើងនូវអ្វីដែលព្រះយេស៊ូវបានធ្វើសំរាប់យើង កាលទ្រង់នៅលើឈើឆ្កាង ។ ព្រះទ្រង់បានលះបង់ជីវិតទ្រង់ ដើម្បីបើកផ្លូវឱ្យយើងបានសង្គ្រោះរួចពីបាប ។ អស់អ្នកណាដែលទទួលបុណ្យដែលព្រះយេស៊ូវធ្វើជំនួសយើង នោះទ្រង់នឹងទទួលអ្នកនោះ ។ នេះគឺជាវិធីនៃសេចក្តីសង្គ្រោះតែមួយគត់ ដែលព្រះអម្ចាស់ទទួលយក ។ ការធ្វើកិច្ចការល្អ និងព្យាយាម ដើម្បីឱ្យបានបុណ្យកុសលនោះ គឺព្រះមិនទទួលយកនៅក្នុងព្រះនេត្រទ្រង់នោះឡើយ ។ មានព្រះដ៏ពិតតែមួយគត់ ដែលអាចសងថ្លៃលោះបាបរបស់យើងបាន គឺជាព្រះយេស៊ូវគ្រីសនោះឯង ដែលបរិសុទ្ធ ហើយអាចថ្វាយអង្គទ្រង់សំរាប់យើងទាំងអស់គ្នាបាន។

សូមអាន កិច្ចការ ៤:១២

ហើយគ្មានសេចក្តីសង្គ្រោះ ដោយសារអ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាននាមឈ្មោះណាទៀតបានប្រទានមកមនុស្ស ឱ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ ។

## សំណួរ :

១. មុនពេលសាវ័កប៉ុលជឿលើព្រះយេស៊ូវ តើគាត់ជាមនុស្សដូចម្តេច ?

២. តើមានការយល់ខុសអ្វីខ្លះ ដែលនាំឱ្យមនុស្សអះអាងថា ខ្លួនជឿលើព្រះគ្រីស្ទ ?

៣. តើអ្វីដែលនាំឱ្យមានការដាច់ចេញពីព្រះ ការឈឺចាប់ និងសេចក្តីស្លាប់នៅក្នុងលោកិយ ?

៤. តើអ្នកត្រូវបានបែកចេញពីព្រះឬ ? តើអ្នកបានប្រព្រឹត្តអំពើបាបទាស់នឹងព្រះដែរឬទេ ?

៥. តើសេចក្តីសន្យាទី១ ដែលព្រះយេស៊ូវទ្រង់សន្យាចំពោះអ្នកជឿនោះ គឺជាអ្វី ?

៦. ហេតុអ្វីយើងត្រូវការរួចពីបាបរបស់យើង ?

៧. តើយើងនឹងត្រូវការពេលយូរប៉ុណ្ណាទៅ ដើម្បីសងថ្លៃលោះបាបរបស់យើងឱ្យរួច ?

៨. តើនរណាជាអ្នកសងថ្លៃលោះបាបរបស់យើង ដែលធ្វើឱ្យយើងអាចទទួលនូវការអភ័យទោសបាន ?

៩. ហេតុអ្វីបានជាព្រះយេស៊ូវអាចសងថ្លៃលោះបាបទាំងអស់របស់យើងបាន ?

១០. តើមាននរណាផ្សេងទៀតក្រៅពីព្រះយេស៊ូវ ដែលអាចជួយសង្គ្រោះយើងឱ្យរួចផុតពីអំពើបាបបានឬទេ ?

# មេរៀនទី២--ហេតុអ្វីបានជាយើងត្រូវតែជឿលើព្រះគ្រីស្ទ?

## ផ្នែកទី២: មរតកនៃពួកបរិសុទ្ធ

នៅក្នុងមេរៀនទី១ យើងបានដឹងថា ព្រះយេស៊ូវបានសន្យាអភ័យទោសចំពោះអំពើបាបនៃអស់អ្នកណាដែលជឿជាក់លើទ្រង់យ៉ាងពិតប្រាកដមែន ។ នៅក្នុងមេរៀននេះ យើងនឹងសម្លឹងមើលទៅការសន្យាទី២ ដែលព្រះយេស៊ូវប្រទានដល់អស់អ្នកណាដែលប្រែចិត្ត និងទុកចិត្តលើទ្រង់ ។ ចូរយើងអាននៅក្នុងខគម្ពីរទាំងឡាយ ដែលយើងបានរៀននៅក្នុងមេរៀនមុន នៅពេលព្រះយេស៊ូវគ្រីស្ទបានបង្គាប់លោកប៉ុលឱ្យទៅផ្សាយដំណឹងល្អ ដល់ប្រជាជាតិទាំងឡាយ ។

សូមអាន កិច្ចការ ២៦:១៦-១៨

ចូរក្រោកឈរឡើង ដ្បិតខ្ញុំបានលេចមកឱ្យអ្នកឃើញ ដើម្បីនឹងតាំងអ្នកឱ្យធ្វើជាអ្នកបំរើ ហើយជាទីបន្ទាល់ពីអស់ទាំងការដែលអ្នកបានឃើញហើយ ព្រមទាំងការដែលខ្ញុំនឹងលេចមកឱ្យអ្នកឃើញទៅមុខទៀត ខ្ញុំបានញែកអ្នកចេញពីបណ្តាជន និងពីពួកសាសន៍ដទៃ ដើម្បីនឹងចាត់អ្នកឱ្យទៅឯគេវិញ ប្រយោជន៍នឹងបំភ្លឺភ្នែកគេ ឱ្យបានបែរចេញពីសេចក្តីងងឹត មកឯពន្លឺ ហើយពីអំណាចអារក្សសាតាំង មកឯព្រះវិញ ដើម្បីឱ្យគេបានរួចពីបាប ហើយបានទទួលមរដក ជាមួយនឹងពួកអ្នកដែលបានញែកជាបរិសុទ្ធ ដោយសារសេចក្តីជំនឿជឿដល់ខ្ញុំ ។

សេចក្តីសន្យាទី២ដែលទ្រង់បានសន្យាដល់អ្នកជឿ គឺមានចែងនៅក្នុងផ្នែកចុងក្រោយនៃខ១៨ ។ ព្រះយេស៊ូវមានបន្ទូលទៅកាន់លោកប៉ុលឱ្យផ្សាយដំណឹងល្អប្រាប់ដល់ប្រជាជន ដើម្បីឱ្យពួកគេអាចនឹងទទួលបាននូវការរួចពីបាប ហើយទទួលបាននូវមរតក ។

# ២. សេចក្តីសន្យាទី២ : មរតក

## ក. តើអ្វីទៅជាមរតក ?

អស់អ្នកដែលជឿលើព្រះគ្រីស្ទនឹងទទួលបាននូវមរតក ។ នេះគឺជាសេចក្តីសន្យាទី២របស់ព្រះ ។ ពេលដែលយើងនិយាយពីមរតក យើងតែងតែគិតពីទ្រព្យសម្បត្តិ លុយកាក់ ដែលឪពុកម្តាយបានបន្សល់ទុកឱ្យ ក្រោយពេលដែលគាត់បានទទួលមរណៈភាព ។ ដូច្នេះ មរតកគឺជារបស់ទ្រព្យទាំងឡាយណាដែលយើងមិនរកមក តែវាជារបស់ទ្រព្យដែលអ្នកផ្សេងបានបន្សល់ទុកឱ្យ ។

ព្រះជាម្ចាស់បានប្រទានមរតកដល់កូនរបស់ទ្រង់ ។ ដូច្នេះ យើងមិនបានខិតខំរកមរតកនេះទេ ព្រោះព្រះយេស៊ូវជាអ្នកដែលបានរកមរតកនោះសម្រាប់យើងតាមរយៈព្រះជន្ម និងការសុគតរបស់ទ្រង់ ។ មរតកនេះមាន២ផ្នែកៈ ប្រាក់កក់ដំបូង ដែលយើងនឹងទទួលបានខណៈដែលយើងកំពុងរស់នៅ និងមរតកពេញលេញ ដែលយើងនឹងទទួលក្រោយពេលយើងស្លាប់ ។

## ខ. តើប្រាក់កក់ដំបូងនៃមរតករបស់យើងគឺជាអ្វី ?

យើងមិនទទួលបានមរតករបស់យើងទាំងអស់នៅពេលឥឡូវនេះទេ តែយើងនឹងទទួលបានប្រាក់កក់ដំបូង ។

ឧទាហរណ៍ ប្រទេសជឿនលឿនខ្លះជួយដល់ប្រទេសផ្សេងៗ ដែលត្រូវការជំនួយក្នុងការអភិវឌ្ឍន៍ ។ បើសិនថ្ងៃណាមួយ ប្រទេសជប៉ុនធ្វើកិច្ចព្រមព្រៀងផ្តល់ជំនួយ $៥០,000 ដើម្បីជួយកិច្ចការអភិវឌ្ឍន៍ណាមួយ ប៉ុន្តែគេឱ្យតែ $១០,000មុន ហើយគេប្រាប់ថា គេនឹងផ្តល់ $៤០,000ទៀតនៅពេលក្រោយ ។ ដូច្នេះ $១០,000ដែលគេផ្តល់ឱ្យដំបូងនោះ គឺជាប្រាក់កក់ដំបូងនៃចំនួនប្រាក់ដែលប្រទេសជប៉ុននឹងផ្តល់ជូននៅពេលអនាគត ។

ពេលព្រះយេស៊ូវសង្គ្រោះយើងឱ្យរួចពីអំពើបាប ទ្រង់បានប្រទានឱ្យយើងនូវប្រាក់កក់ដំបូងរួចស្រេចទៅហើយ ដូចជាមានភស្តុតាងបង្ហាញថា មានមរតកបន្ថែមទៀតនឹងមកតាមក្រោយ ។ មនុស្សខ្លះមិនបានរក្សានូវកិច្ចសន្យារបស់ពួកគេទេ តែព្រះយេស៊ូវក៏មិនដែលភ្លេចសន្យាដែរ ព្រោះទ្រង់គឺជាព្រះដ៏ស្មោះត្រង់ និងមានអំណាចលើអ្វីៗទាំងអស់ ។

តើប្រាក់កក់ដំបូងដែលព្រះគ្រីស្ទបានប្រទានដល់កូនទ្រង់ម្នាក់ៗនោះ គឺជាអ្វី ?

### គឺការយាងចូលសណ្ឋិតនៅរបស់ព្រះវិញ្ញាណបរិសុទ្ធ ។

ព្រះមិនមែនគ្រាន់តែលើកលែងទោសនូវអំពើបាបរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏ប្រទានឱ្យយើងនូវទ្រព្យសម្បត្តិដ៏មានតម្លៃខ្ពស់ជាងគេបំផុតគឺ ព្រះវិញ្ញាណបរិសុទ្ធនៃទ្រង់បានយាងមកសណ្ឋិតជាមួយយើង ។ បន្ទាប់ពីព្រះយេស៊ូវសុគត ហើយមានព្រះជន្មរស់ឡើងវិញ ទ្រង់បានប្រទានដល់អស់អ្នកណាដែលជឿនូវអំណោយនៃព្រះវិញ្ញាណបរិសុទ្ធ ជាប្រាក់កក់ដំបូងនៃមរតកដែលទ្រង់បានសន្យា ។

សូមអាន អេភេសូរ ១:១៣-១៤ក

ឯអ្នករាល់គ្នា ក៏បានឮព្រះបន្ទូលនៃសេចក្ដីពិត គឺជាដំណឹងល្អពីសេចក្ដីសង្គ្រោះរបស់អ្នករាល់គ្នា ដោយសារទ្រង់ដែរ ហើយកាលអ្នករាល់គ្នាបានជឿហើយ នោះទ្រង់ក៏ដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធ ដែលបានសន្យា ព្រះវិញ្ញាណបរិសុទ្ធនោះ ទ្រង់ជាទីបញ្ចាំចិត្ត ពីដំណើរកេរ្តិ៍អាកររបស់យើងរាល់គ្នា ។

ព្រះវិញ្ញាណបរិសុទ្ធគឺជាវត្ថុបញ្ចាំចិត្តនៃអ្វីដែលយើងនឹងត្រូវទទួលបានជាមរតកពីព្រះអង្គ ។ ព្រះវិញ្ញាណនៃទ្រង់យាងមកគង់នៅក្នុងពួកអ្នកជឿលើព្រះ គឺក្នុងខណៈពេលដែលគាត់ទើបតែទទួលជឿលើព្រះយេស៊ូវ ដើម្បីរួចពីអំពើបាប ។ អស់អ្នកណាដែលជឿលើព្រះយេស៊ូវមិនត្រូវខ្លាចវិញ្ញាណអាក្រក់ ឬអារក្សសាតាំងឡើយ ដ្បិតព្រះវិញ្ញាណដែលមានអំណាចលើសលប់នោះ រស់នៅក្នុងខ្លួនយើង ។

<u>សូមអាន យ៉ូហានទី១ ៤:៤</u>

ពួកកូនតូចៗអើយ អ្នករាល់គ្នាមកពីព្រះ ហើយក៏ឈ្នះវិញ្ញាណទាំងនោះដែរ ពីព្រោះព្រះដែលគង់ក្នុងអ្នករាល់គ្នា នោះទ្រង់ធំជាងអានោះ ដែលនៅក្នុងលោកិយផង ។

ព្រះបន្ទូលរបស់ទ្រង់ពន្យល់ថា រូបកាយរបស់យើងគឺជាវិហារនៃព្រះវិញ្ញាណបរិសុទ្ធ ។ ដូច្នេះ ជីវិតរបស់យើងត្រូវតែបរិសុទ្ធ ពីព្រោះព្រះវិញ្ញាណរបស់ទ្រង់ ដែលអាស្រ័យនៅក្នុងយើង គឺល្អបរិសុទ្ធ ។

<u>សូមអាន កូរិនថូសទី១ ៦:១៩-២០</u>

តើមិនដឹងទេឬអីថា រូបកាយអ្នករាល់គ្នាជាវិហារនៃព្រះវិញ្ញាណបរិសុទ្ធ ដែលអ្នករាល់គ្នាបានទទួលមកពីព្រះ ហើយអ្នករាល់គ្នាមិនមែនជារបស់ផងខ្លួនទេ ត្បិតព្រះទ្រង់បានចេញថ្លៃលោះអ្នករាល់គ្នាហើយ ដូច្នេះ ចូរតំកើងព្រះនៅក្នុងរូបកាយនៃអ្នករាល់គ្នា ។

តើការគង់នៅនៃព្រះវិញ្ញាណបរិសុទ្ធ ដែលជាប្រាក់កក់ដំបូងនៃមរតកក្នុងព្រះគ្រីស្ទ នោះមានផលប្រយោជន៍អ្វីខ្លះ ? ផលប្រយោជន៍នោះគឺ

## ១ ព្រះវិញ្ញាណបរិសុទ្ធប្រទានឱ្យយើងនូវជីវិតដ៏នៅអស់កល្បជានិច្ច

<u>សូមអាន យ៉ូហាន ៥:២៤</u>

ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលស្ដាប់ពាក្យខ្ញុំ ហើយជឿដល់ព្រះអង្គដែលចាត់ខ្ញុំមក អ្នកនោះមានជីវិតដ៏នៅអស់កល្បជានិច្ច ហើយមិនដែលត្រូវជំនុំជំរះឡើយ គឺបានកន្លងហួសពីសេចក្ដីស្លាប់ ទៅដល់ជីវិតវិញ ។

ព្រះអម្ចាស់ប្រទានដល់កូនចៅរបស់ទ្រង់គ្រប់រូបនូវជីវិតដ៏នៅអស់កល្បជានិច្ច ។ ពេលយើងជឿលើព្រះគ្រីស្ទ ព្រះប្រទានឱ្យយើងនូវជីវិតដ៏នៅអស់កល្បជានិច្ចភ្លាមៗនេះតែម្ដង !

ព្រះយេស៊ូវបានប្រទានដល់យើងនូវជីវិតរបស់ផងទ្រង់ ដើម្បីនៅពេលណាដែលយើងស្លាប់ទៅ យើងអាចត្រលប់ទៅរស់នៅជាមួយទ្រង់នៅឋានសួគ៌បាន ។ រូបកាយរបស់យើងនឹងនៅតែស្លាប់ ប៉ុន្តែព្រលឹងរបស់យើងនឹងមិនដែលស្លាប់ឡើយ ។ យើងមិនត្រូវខ្លាចសេចក្ដីស្លាប់ឡើយ ដ្បិតព្រះអម្ចាស់ប្រទានដល់យើងនូវជីវិតដ៏នៅអស់កល្បជានិច្ច ។

មនុស្សនៅក្នុងលោកិយមានសេចក្ដីភ័យខ្លាចចំពោះសេចក្ដីស្លាប់ណាស់ ។ មនុស្សជាច្រើនគិតថា វាគឺជាសំណាងអាក្រក់ បើនិយាយអំពីសេចក្ដីស្លាប់នោះ ។ មនុស្សជាច្រើនបានចំណាយប្រាក់កាសដ៏ច្រើន ដើម្បីព្យាយាមការពារខ្លួនឯងពីគ្រោះថ្នាក់ និងពីជំងឺរោគាផ្សេងៗ ដោយការទិញនូវខ្សែចង្កេះ ខ្សែសីមា ព្រលែងសត្វ ឬសាក់យន្ដ័ជាដើម ។ ហេតុអ្វីគេធ្វើដូច្នេះ ? គឺព្រោះតែពួកគេមានការភ័យខ្លាចចំពោះគ្រោះថ្នាក់ ឬសេចក្ដីស្លាប់ ដែលនឹងកើតឡើងនៅក្នុងជីវិតរបស់គេ ។ អស់អ្នកណាដែលមានជីវិតដ៏នៅអស់កល្បជានិច្ច នឹងមិនត្រូវខ្លាចសេចក្ដីស្លាប់ឡើយ ព្រោះអីការស្លាប់ វាគឺជាការត្រលប់ទៅឯព្រះនៅឋានសួគ៌ ។ អ្នកជឿមានសេចក្ដីសោកស្ដាយនៅពេលដែលមានគ្រីស្ទានម្នាក់ទទួលមរណៈភាព តែយើងមិនមានសេចក្ដីសោកសង្រេង ដូចជាលោកិយនោះឡើយ ។ យើងដឹងពីកន្លែងដែលអ្នកជឿត្រូវទៅ ហើយយើងក៏នឹងជួបពួកគេសារជាថ្មីម្ដងទៀតនៅទីនោះផងដែរ ។

<u>សូមអាន ថែស្សាឡូនីចទី១ ៤:១៣</u>

បងប្អូនអើយ ខ្ញុំមិនចង់ឲ្យអ្នករាល់គ្នាឥតដឹងពីពួកអ្នកដែលដេកលក់ (ស្លាប់) ទៅហើយទេ ក្រែងអ្នករាល់គ្នាកើតទុក្ខព្រួយ ដូចជាអ្នកឯទៀត ដែលគ្មានសង្ឃឹម ។

## ២ ព្រះវិញ្ញាណបរិសុទ្ធបំផ្លាស់បំប្រែចិត្ត និងការប្រព្រឹត្តរបស់យើង នៅពេលឥឡូវនេះ

ព្រះវិញ្ញាណបរិសុទ្ធមកគង់នៅជាមួយយើង ដើម្បីបំផ្លាស់ចិត្តគំនិតរបស់យើង ហើយនាំយើងឱ្យរស់នៅក្នុងសេរីភាពពីអំណាចនៃអំពើបាប ។ សាសនារបស់លោកិយបង្រៀនអំពីការចាំបាច់នៃការកែប្រែចេញពីផ្លូវបាប ក៏ប៉ុន្តែសាសនាមិនអាចជួយយើងឱ្យផ្លាស់ប្រែបាននោះទេ ។ យើងត្រូវការព្រះវិញ្ញាណបរិសុទ្ធជួយយើង ដើម្បីកែប្រែជីវិតនេះ ហើយឱ្យមានជីវិតពេញដោយសេចក្ដីស្រឡាញ់ និងភាពបរិសុទ្ធ ដើម្បីថ្វាយសិរីល្អដល់ព្រះ ។

<u>សូមអាន កាឡាទី ៥:១៩-២៤</u>

រីឯកិច្ចការខាងសាច់ឈាម នោះប្រាកដច្បាស់ហើយ គឺជាសេចក្តីកំផិត សហាយស្មន់ ស្មោកគ្រោក អាសអាភាស ថ្វាយបង្គំរូបព្រះ មន្តអាគម សំអប់គ្នា ឈ្លោះប្រកែក ឈ្នានីស កំហឹង ទាស់ទែងគ្នា បាក់បែក បក្សពួក ច្រណែន កាប់សំលាប់ ប្រមឹក ស៊ីផឹកជ្រុល នឹងការអ្វីទៀត ដែលស្រដៀងនឹងសេចក្តីទាំងនេះផង ហើយខ្ញុំប្រាប់អ្នករាល់គ្នាទុកជាមុន ដូចជាបានប្រាប់រួចមកហើយថា អស់អ្នកដែលប្រព្រឹត្តដូច្នេះ នោះមិនបានគ្រងនគរព្រះ ទុកជាមរតកឡើយ តែឯផលផ្លែនៃព្រះវិញ្ញាណវិញ នោះគឺសេចក្តីស្រលាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត ហើយដឹងខ្នាត គ្មានក្រិត្យវិន័យណាទាស់នឹងសេចក្តីយ៉ាងនោះទេ ហើយអស់អ្នកដែលជារបស់ផងព្រះគ្រីស្ទ នោះបានឆ្កាងសាច់ឈាមហើយ ព្រមទាំងសេចក្តីរំជួល នឹងសេចក្តីប៉ងប្រាថ្នាទាំងប៉ុន្មានផង ។

ព្រះវិញ្ញាណនៃទ្រង់បង្រៀនយើងឱ្យស្គាល់ ហើយមានសេចក្តីប្រកបជាមួយនឹងព្រះនៅពេលឥឡូវនេះ ។ ទ្រង់បង្រៀនយើងឱ្យចេះលះបង់អំពើបាប ដែលយើងធ្លាប់ប្រព្រឹត្ត ហើយនាំឱ្យយើងស្គាល់សេចក្តីអំណរ និងសេចក្តីសុខសាន្តដ៏ពិតរបស់ទ្រង់ ។ ចំនុចទាំងនេះ សាសនា និងលោកិយជួយយើងមិនបានទេ ។ យើងត្រូវការព្រះពរពីព្រះវិញ្ញាណបរិសុទ្ធ ។ នៅពេលដែលយើងទទួលជឿព្រះយេស៊ូវ ភ្លាមនោះ ព្រះអង្គចាប់ផ្តើមបំផ្លាស់ចិត្តរបស់យើង ដោយព្រះគុណនៃព្រះប្រយោជន៍ឱ្យយើងកែខ្លួន ដើម្បីគោរព និង ថ្វាយជីវិតដល់ទ្រង់ជារៀងរាល់ថ្ងៃ ។ ភាពបរិសុទ្ធ សេចក្តីអំណរ និង សេចក្តីសុខសាន្តគ្រប់ពេលវេលា គឺជាមរតកក្នុងព្រះគ្រីស្ទ ដែលយើងនឹងទទួលពីព្រះអង្គមកនៅពេលដែលយើងចូលនគរឋានសួគ៌ ។

## គ. តើអ្វីទៅជាមរតកនៅពេលអនាគត ?

<u>សូមអាន ពេត្រុសទី១ ១:៣-៤</u>

សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានបង្កើតយើងឡើងជាថ្មី តាមសេចក្តីមេត្តាករុណាដ៏ធំរបស់ទ្រង់ ដើម្បីឱ្យយើងរាល់គ្នាបានសេចក្តីសង្ឃឹមដ៏រស់ ដោយសារព្រះយេស៊ូវគ្រីស្ទ ទ្រង់រស់ពីស្លាប់ឡើងវិញ ហើយឱ្យយើងបានមរតក ដែលមិនចេះពុករលួយក៏ឥតសៅហ្មង ហើយមិនដែលស្រពោនឡើយ ជាមរតកដែលបំរុងទុកឱ្យយើងរាល់គ្នានៅស្ថានសួគ៌ ។

មរតកនៅពេលអនាគត គឺជាពរជ័យមួយដែលនឹងមិនបាត់ឡើយ ។ យើងនឹងមានមរតកនោះរហូត ដូចជាយើងនឹងនៅជាមួយព្រះអម្ចាស់រហូតដែរ ។ ម្យ៉ាងវិញទៀត មរតកនៅពេលអនាគតរបស់យើង គឺមិនអាចពិពណ៌នាបានឡើយ យើងអាចបានត្រឹមតែមានសេចក្តីអំណរ រីករាយ

និងកានោះប៉ុណ្ណោះ ។ យើងនឹងឃើញព្រះ ហើយនិងថ្វាយបង្គំទ្រង់ ព្រមទាំងរីករាយជាមួយនឹងទ្រង់រហូតតទៅ ។ ទ្រង់នឹងប្រទានដល់យើងនូវរូបកាយមួយថ្មី ដែលពុំមានអំពើបាប ។ ទ្រង់នឹងបង្កើតឋានសួគ៌ និងផែនដីថ្មី ដែលជាកន្លែងគ្មានការឈឺចាប់ គ្មានការរងទុក្ខវេទនា គ្មានអំពើបាប ឬសេចក្តីស្លាប់ឡើយសំរាប់យើង ។ យើងនឹងបានជៀសផុតពីទុក្ខវេទនា ដែលមកពីបណ្តាសារ ដោយសារអំពើបាបជារៀងរហូត ។ យើងនឹងមិនបាត់បង់នូវមរតកនេះទេ ។

សូមអាន ពេត្រុសទី២ ៣:១៣-១៤

តែតាមសេចក្តីសន្យារបស់ទ្រង់ នោះយើងរាល់គ្នាទន្ទឹងចាំផ្ទៃមេឃថ្មី នឹងផែនដីថ្មី ដែលមានសុទ្ធតែសេចក្តីសុចរិតវិញ ដូច្នេះ ឱពួកស្ងួនភ្ងាអើយ ដែលទន្ទឹងចាំសេចក្តីទាំងនោះ ចូរមានចិត្តឧស្សាហ៍ ឱ្យទ្រង់បានឃើញអ្នករាល់គ្នាជាឥតសៅហ្មង ហើយឥតកន្លែងបន្ទោសបាន ទាំងមានសេចក្តីមេត្រីផង ។

សំណួរ :

១. តើចំនុច២យ៉ាង ដែលព្រះទ្រង់សន្យានឹងប្រទានដល់អស់អ្នកណាដែលជឿលើទ្រង់នោះ គឺជាអ្វី ?

២. តើនរណាដែលព្រះយេស៊ូវបានប្រទានដល់យើង ជាប្រាក់កក់ដំបូងនៃមរតក ?

៣. ហេតុអ្វីបានជាអ្នកគ្រីស្ទានមិនគួរខ្លាចវិញ្ញាណអាក្រក់ ?

៤. តើវិហារនៃព្រះវិញ្ញាណបរិសុទ្ធនៅទីណា ?

៥. តើកិច្ចការអ្វីខ្លះដែលព្រះវិញ្ញាណបរិសុទ្ធធ្វើ ពេលដែលទ្រង់យាងមកគង់នៅជាមួយអ្នកជឿ ?

៦. តើជីវិតដ៏នៅអស់កល្បជានិច្ចមានន័យថា រូបកាយរបស់យើងមិនចេះស្លាប់មែនឬទេ ?

៧. តើមនុស្សលោកបង្ហាញថា ពួកគេមានសេចក្តីភ័យខ្លាចចំពោះសេចក្តីស្លាប់យ៉ាងដូចម្តេច ?

៨. តើពួកគ្រីស្ទានគួរតែខ្លាចចំពោះសេចក្តីស្លាប់ដែរឬទេ ? ហេតុអ្វី ?

៩. តើអ្នកណាអាចជួយយើងឱ្យមានសេចក្តីស្រឡាញ់ អំណរ និង សេចក្តីសុខសាន្តដ៏ពិតក្នុងជីវិតនេះបាន ?

១០. តើមរតកនៅពេលអនាគត គឺជាអ្វី ?

# មេរៀនទី៣--ការកែប្រែចិត្តពិតប្រាកដ

អស់អ្នកណាដែលបានរួចពីបាប ហើយបានទទួលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់របស់ពួកគេ នឹងមានចិត្តចង់គោរពធ្វើតាមព្រះ ។ ព្រះបន្ទូលរបស់ព្រះបានបង្គាប់យើងឱ្យចេះថ្លែងអរព្រះគុណដល់ព្រះ សម្រាប់ការកែប្រែចិត្ត ។ អស់មនុស្សទាំងឡាយណា ដែលមានសេចក្ដីជំនឿពិតប្រាកដទៅលើព្រះគ្រីស្ទ នឹងទទួលផលនៃការប្រែចិត្ត ។

មុនគាត់ជឿលើព្រះយេស៊ូវ លោកប៉ុលបានស្អប់ ហើយបានបៀតបៀនដល់ពួកគ្រីស្ទាន ។ ក្រោយមក ព្រះយេស៊ូវបានបង្ហាញរូបអង្គទ្រង់ឱ្យសាវ័កប៉ុលបានឃើញ បន្ទាប់ពីនោះ គាត់ក៏បានផ្លាស់ប្រែចិត្តជឿលើទ្រង់ ព្រមទាំងក្លាយជាអ្នកផ្សាយដំណឹងល្អ ។ ចូរយើងអានពីទីបន្ទាល់របស់លោកប៉ុល ពេលគាត់រៀបរាប់ ព្រះរាជាអ័គ្រីប៉ាអំពីសេចក្ដីសង្គ្រោះក្នុងព្រះ ហើយនិងអំពីបេសកកម្ម ដែលគាត់ត្រូវបានទទួលពីព្រះយេស៊ូវ ។

<u>សូមអាន កិច្ចការ ២៦:១៣-១៨</u>

នោះបពិត្រព្រះករុណាអើយ នៅពេលថ្ងៃត្រង់ហើយ ដែលទូលបង្គំកំពុងដើរ នោះស្រាប់តែមានពន្លឺពីលើមេឃ ភ្លឺមកជុំវិញទូលបង្គំ នឹងពួកអ្នកដើរជាមួយ ជាពន្លឺភ្លឺជាងថ្ងៃ  ទូលបង្គំទាំងអស់គ្នាក៏ដួលដល់ដី រួចទូលបង្គំឮសំលេង មានបន្ទូលមក ជាភាសាហេព្រើរថា  សុល នែសុល ហេតុអ្វីបានជាធ្វើទុក្ខដល់ខ្ញុំ   ដែលធ្លាក់ជល់នឹងជន្លួញដូច្នេះ នោះពិបាកដល់អ្នកណាស់   ទូលបង្គំក៏ឆ្លើយថា ឱព្រះអម្ចាស់អើយ តើព្រះអង្គណាន៎ុះ រួចទ្រង់មានបន្ទូលថា ខ្ញុំនេះជាព្រះយេស៊ូវ ដែលអ្នកធ្វើទុក្ខ ចូរក្រោកឈរឡើង ដ្បិតខ្ញុំបានលេចមកឱ្យអ្នកឃើញ ដើម្បីនឹងតាំងអ្នក ឱ្យធ្វើជាអ្នកបំរើ ហើយជាទីបន្ទាល់ពីអស់ទាំងការដែលអ្នកបានឃើញហើយ  ព្រមទាំងការដែលខ្ញុំនឹងលេចមក ឱ្យអ្នកឃើញទៅមុខទៀត ខ្ញុំបានញែកអ្នកចេញពីបណ្ដាជន និងពីពួកសាសន៍ដទៃ ដើម្បីនឹងចាត់អ្នកឱ្យទៅឯគេវិញ ប្រយោជន៍នឹងបំភ្លឺភ្នែកគេ ឱ្យបានបែរចេញពីសេចក្ដីងងឹត មកឯពន្លឺ ហើយពីអំណាចអារក្សសាតាំង មកឯព្រះវិញ ដើម្បីឱ្យគេបានរួចពីបាប ហើយបានទទួលមរដក ជាមួយនឹងពួកអ្នកដែលបានញែកជាបរិសុទ្ធ ដោយសារសេចក្ដីជំនឿជឿដល់ខ្ញុំ ។

សូមរំលឹកឡើងវិញពីអ្វីដែលបានកើតឡើងចំពោះប៉ុលនៅក្នុងខទាំងនេះ ។

លោកប៉ុលមិនមែនមិនគោរពចំពោះព្រះយេស៊ូវនោះទេ ។ គាត់បានជឿ ហើយគោរពតាមព្រះបន្ទូលរបស់ព្រះ ។ ទ្រង់បានត្រាស់ហៅគាត់ឱ្យបំរើព្រះអង្គក្នុងការផ្សាយដំណឹងល្អទៅគ្រប់ទាំងសាសន៍ ។ សូមអ្នកយកចិត្តទុកដាក់ទៅលើរបៀបដែលសាវ័កប៉ុលប្រកាសព្រះបន្ទូលរបស់ព្រះទៅកាន់សាសន៍ផ្សេងៗ ។

សូមអាន កិច្ចការ ២៦:១៩-២០

ដូច្នេះ បពិត្រព្រះរាជាអ័គ្រីប៉ាអើយ ទូលបង្គំមិនបានចចេសនឹងការជាក់ស្តែងពីស្ថានសួគ៌នោះទេ គឺទូលបង្គំបានប្រាប់ឱ្យមនុស្សទាំងអស់ប្រែចិត្ត ហើយងាកបែរមកឯព្រះវិញ ទាំងប្រព្រឹត្តបែបសំណំនឹងការប្រែចិត្តផង គឺប្រាប់ដល់ពួកអ្នកដែលនៅក្រុងដាម៉ាសជាមុនដំបូង រួចនៅក្រុងយេរូសាឡិមនឹងគ្រប់ក្នុងខេត្តយូដា ហើយដល់អស់ទាំងសាសន៍ដទៃផង ។

នៅពេលដែលលោកប៉ុលប្រកាសដំណឹងល្អ តើលោកបានប្រាប់ប្រជាជននៅតាមកន្លែងផ្សេងៗឱ្យធ្វើអ្វីខ្លះ ? គាត់បានប្រាប់ពួកគេឱ្យកែប្រែចិត្តពីអំពើបាបរបស់ពួកគេ ព្រមទាំងអ្នកជឿសាសនាដទៃឱ្យបែរទៅរកព្រះវិញ ។ គាត់ក៏បានប្រាប់ពួកគេផងដែរថា ពួកគេត្រូវតែគោរពព្រះដោយផលផ្លែនៃការប្រែចិត្ត ។ អ្នកទាំងឡាយណាដែលពិតជាប្រែចិត្ត ហើយជឿពិតប្រាកដនឹងមានការផ្លាស់ប្តូរក្នុងជីវិត ។ ហេតុអ្វីក៏ដូច្នេះ ? ពីព្រោះពួកគេបានងាកចេញពីផ្លូវចាស់របស់ពួកគេ ដើម្បីទៅរកផ្លូវរបស់ព្រះ ហើយបានទទួលជីវិតដ៏អស់កល្បជានិច្ចនៅក្នុងព្រះយេស៊ូវ ។ ឥឡូវនេះ ព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយពួកគេ ហើយកំពុងតែធ្វើការផ្លាស់ប្តូរពួកគេឱ្យដូចជាព្រះយេស៊ូវវិញ ។

សូមអាន កូរិនថូសទី២ ៥:១៧

បានជាបើអ្នកណានៅក្នុងព្រះគ្រីស្ទ នោះឈ្មោះថាបានកើតជាថ្មីហើយ អស់ទាំងសេចក្តីចាស់បានកន្លងបាត់ទៅ មើលគ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ ។

ចូរក្រឡេកមើលឧទាហរណ៍នៃអ្នកជឿលើព្រះយេស៊ូវថ្មីពីរក្រុម ដែលបានសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅនៃការប្រែចិត្តចំពោះព្រះអង្គ ។

## ឧទាហរណ៍ទី១——ពួកអ្នកជឿនៅក្នុងទីក្រុងអេភេសូរ

សូមអាន កិច្ចការ ១៩:១១-២០

ហើយព្រះទ្រង់ធ្វើការឫទ្ធិបារមីយ៉ាងប្លែកៗ ដោយសារដៃប៉ុល ដល់ម្ល៉េះបានជាគេគ្រាន់តែយកកន្សែង ឬក្រមាពីខ្លួនគាត់ ទៅដាក់លើមនុស្សមានជំងឺ នោះគេក៏បានជា ហើយមានអារក្សអសោចិ៍ចេញពីមនុស្សដែររីឯមនុស្សសាសន៍យូដាខ្លះ ជាគ្រូមន្តអាគមដែលដើរចុះឡើង គេក៏ចាប់តាំងអំពាវនាវដល់ព្រះនាម

ព្រះអម្ចាស់យេស៊ូវ ពីលើមនុស្សដែលមានអារក្សអសោចិ៍ចូលថា អញបង្គាប់ឯង ដោយនូវព្រះយេស៊ូវ ដែលប៉ុលប្រកាសប្រាប់នោះ ក្នុងពួកមនុស្សដែលធ្វើដូច្នោះ មានប្រាំ២នាក់ ជាកូននៃសាសន៍យូដាម្នាក់ ដែលធ្វើជាសង្គ្រាជឈ្មោះស្កេវ៉ា តែអារក្សអសោចិ៍ឆ្លើយទៅគេថា យើងស្គាល់ព្រះយេស៊ូវហើយ ហើយស្គាល់ប៉ុលបន្តិចបន្តួចដែរ តែឯឯងរាល់គ្នា តើជាអ្នកណាវិញ រួមមនុស្សដែលមានអារក្សអសោចិ៍ចូល ក៏ស្ទុះទៅលើគេ ទាំងបង្ក្រប ហើយឈ្នះគេ ដល់ម្ល៉េះបានជាគេរត់គេចចេញពីផ្ទះនោះទាំងអាក្រាត ហើយមានរបួសផង ។ ឯអស់មនុស្សដែលនៅក្រុងអេភេសូរ ទាំងសាសន៍យូដា និងសាសន៍ក្រេកផង បានដឹងរឿងនោះ ក៏កើតមានចិត្តភ័យខ្លាចទាំងអស់គ្នា ហើយព្រះនាមព្រះអម្ចាស់យេស៊ូវក៏បានថ្កើងឡើង ។ មានមនុស្សជាច្រើនដែលបានជឿ គេមកលន់តួ ព្រមទាំងសំដែងប្រាប់ពីការដែលខ្លួនបានប្រព្រឹត្តផង ។ ឯមនុស្សដែលប្រព្រឹត្តវិជ្ជាប្លែកៗ នោះក៏មានច្រើននាក់ បានយកក្បួនដំរារបស់ខ្លួន មកដុតចោលនៅចំពោះមុខមនុស្សទាំងអស់គ្នា គេបានគិតថ្លៃក្បួនទាំងនោះមើល ឃើញមានដំឡៃអស់៥ម៉ឺនរៀល គឺយ៉ាងដូច្នោះឯង ដែលព្រះបន្ទូលនៃព្រះអម្ចាស់បានចំរើនកើនឡើង ហើយបានឈ្នះដោយអំណាច ។

សូមរំលឹកពីដំណើររឿងនៃពួកអ្នកជឿនៅក្នុងទីក្រុងអេភេសូរ ។

អ្វីដែលបានកើតឡើងនៅអេភេសូរ គឺអស្ចារ្យណាស់ ! អំណាចរបស់ព្រះត្រូវបានបង្ហាញដល់មនុស្សជាច្រើនតាមវិធីខុសៗគ្នា ។ មនុស្សជាច្រើនជឿដំណឹងល្អ ដែលបានផ្សព្វផ្សាយដោយលោកប៉ុលនៅទីនោះ ។ តើពួកគេបានធ្វើអ្វី ដើម្បីបង្ហាញសេចក្តីជំនឿរបស់ពួកគេនៅលើព្រះគ្រីស្ទ ? ពួកគ្រីស្ទានថ្មីនៅក្រុងអេភេសូរ បានបំផ្លាញសៀវភៅសាសនា និងលះបង់ទ្រព្យសម្បត្តិទាំងអស់របស់ពួកគេចោល ទោះបីជាវាមានតម្លៃស្មើនឹងលុយជាច្រើនក៏ដោយ ។ ទ្រព្យសម្បត្តិដែលគេបានបំផ្លាញចោល បើគិតជាលុយរបស់យើងសព្វថ្ងៃនេះ គឺមានតំលៃជាង ៤០,០០០ ដុល្លារ ! ហេតុអ្វីបានជាពួកគេធ្វើដូច្នេះ ? ពួកគេពិតជាបានប្រែចិត្ត ហើយងាកចេញពីការបំរើព្រះមិនពិត ទៅបំរើព្រះដ៏ពិត ដែលមានព្រះជន្មដ៏រស់វិញ ។ ឥឡូវនេះ ព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយពួកគេ ហេតុដូច្នេះហើយបានជាពួកគេមិនចង់ថ្វាយបង្គំវិញ្ញាណអាក្រក់ និង ព្រះដទៃទៀតទេ ។

# ឧទាហរណ៍ទី២——ពួកអ្នកជឿនៅក្រុងថែស្សាឡូនិច

សូមអាន ថែស្សាឡូនិចទី១ ១:៦-១០

អ្នករាល់គ្នាក៏បានត្រាប់តាមយើងខ្ញុំ ហើយនិងព្រះអម្ចាស់ ដោយបានទទួលព្រះបន្ទូល ដោយសេចក្តីអំណររបស់ព្រះវិញ្ញាណបរិសុទ្ធ ក្នុងកាលដែលកំពុងតែកើតទុក្ខលំបាកជាខ្លាំងផង ដល់ម្ល៉េះបានជាអ្នករាល់គ្នាបានត្រឡប់ជាគំរូ ដល់អស់អ្នកដែលជឿនៅស្រុកម៉ាសេដូន និងស្រុកអាខៃ ត្បិតព្រះបន្ទូលនៃព្រះអម្ចាស់បានផ្សាយចេញពីអ្នករាល់គ្នា មិនមែនតែក្នុងស្រុកម៉ាសេដូន និងស្រុកអាខៃប៉ុណ្ណោះទេ គឺរហូតដល់គ្រប់ទាំងកន្លែង

ដែលពួកនិយាយពីសេចក្តីជំនឿរបស់អ្នករាល់គ្នាចំពោះព្រះថែមទៀតផង បានជាមិនចាំបាច់ឱ្យយើងខ្ញុំនិយាយអ្វីទៀតទេ ត្បិតគេថ្លែងប្រាប់ពីយើងខ្ញុំ ដែលអ្នករាល់គ្នាបានទទួលយើងជាយ៉ាងណា ទាំងបែរចេញពីរូបព្រះ មកឯព្រះដ៏ពិត ឱ្យបានគោរពប្រតិបត្តិដល់ព្រះ ដ៏មានព្រះជន្មរស់នៅនោះវិញ ហើយឱ្យបានចាំព្រះរាជបុត្រាព្រះទ្រង់យាងមកពីស្ថានសួគ៌ ដែលព្រះបានប្រោសឱ្យទ្រង់រស់ពីស្លាប់ឡើងវិញ គឺជាព្រះយេស៊ូវ ដែលទ្រង់ប្រោសឱ្យយើងរួចពីសេចក្តីខ្ញាល់ទៅមុខ ។

ទីបន្ទាល់នៃពួកអ្នកជឿទាំងនេះនៅក្នុងក្រុងថែស្សាឡូនីចអស្ចារ្យណាស់ហ្ន៎ ! សូមមើលពីរបៀបដែលពួកគេបែរចេញពីរូបព្រះ ដើម្បីបំរើព្រះដ៏ពិត ដែលមានព្រះជន្មដ៏រស់ ! មនុស្សគ្រប់គ្នាបានដឹងពីការផ្លាស់ប្តូរនៃជំនឿរបស់ពួកគេ ។ ពួកអ្នកជឿពិតប្រាកដទាំងអស់នៅក្នុងព្រះយេស៊ូវគ្រីស្ទ បានងាកចេញពីរូបសំណាក និងផ្លូវនៃជំនឿចាស់របស់ពួកគេ ។ ពួកអ្នកជឿលើព្រះយេស៊ូវគ្រីស្ទពិតប្រាកដ គេនឹងបំរើព្រះអង្គតែមួយប៉ុណ្ណោះ ។ គ្មានករណីលើកលែងនោះទេ ។ គ្មាននរណាម្នាក់អាចបំរើចៅហ្វាយពីរបានទេ ។

ចូរចងចាំថា នៅពេលយើងជឿលើព្រះគ្រីស្ទ ទ្រង់ប្រទានឱ្យយើងនូវព្រះវិញ្ញាណបរិសុទ្ធដើម្បីគង់នៅជាមួយយើង ។ វិញ្ញាណផ្សេងៗទៀតមិនអាចរស់នៅក្នុងព្រះវិហារនៃព្រះវិញ្ញាណបរិសុទ្ធបានទេ ។ អ្នកទាំងឡាយណាដែលចង់បន្តប្រព្រឹត្តតាមផ្លូវចាស់របស់ពួកគេ ហើយបំរើព្រះចាស់ នោះគេមិនទាន់បានកែប្រែចិត្តនិងត្រឡប់ទៅរកព្រះនៅឡើយទេ ទោះបីជាគេនិយាយថា គេជឿក៏ដោយ ។ អស់អ្នកដែលមិនចង់ដើរតាមព្រះយេស៊ូវ ប៉ុន្តែមានបំណងដើរក្នុងអំពើបាបដូចជាលោកិយវិញ អ្នកនោះគ្មានព្រះវិញ្ញាណបរិសុទ្ធអាស្រ័យនៅក្នុងខ្លួនទេ ។ អ្នកនោះមិនមែនជាអ្នកជឿលើព្រះយេស៊ូវដ៏ពិតនោះទេ ។ ការកែប្រែចិត្តមានន័យថាអ្នកនោះមានបំណងបែរចេញពីអំពើបាប ដែលពួកគេបានប្រព្រឹត្តកន្លងមក ។ នៅពេលដែលយើងពិតជាលន់តួបាបព្រះវិញ្ញាណរបស់ព្រះដ៏ជាទីបញ្ចាំចិត្តនៃមរតករបស់យើង ទ្រង់ជួយយើងឱ្យផ្លាស់ប្តូរដោយព្រះគុណរបស់ព្រះអង្គគឺក្នុងន័យឱ្យយើងមានសមត្ថភាពដើរតាមព្រះយេស៊ូវបាន។

<u>សូមអាន កាឡាទី ៥:១៩-២៤</u>

រីឯកិច្ចការខាងសាច់ឈាម នោះប្រាកដច្បាស់ហើយ គឺជាសេចក្តីកំផិត សហាយស្មន់ ស្មោកគ្រោក អាសអាភាសថ្វាយបង្គំរូបព្រះ មន្តអាគម សំអប់គ្នា ឈ្លោះប្រកែក ឈ្នានីស កំហឹង ទាស់ទែងគ្នា បាក់បែក បក្សពួក ច្រណែនកាប់សំលាប់ ប្រមឹក ស៊ីផឹកជ្រុល នឹងការអ្វីទៀត ដែលស្រដៀងនឹងសេចក្តីទាំងនេះផង ហើយខ្ញុំប្រាប់អ្នករាល់គ្នាទុកជាមុន ដូចជាបានប្រាប់រួចមកហើយថា អស់អ្នកដែលប្រព្រឹត្តដូច្នេះ នោះមិនបានគ្រងនគរព្រះទុកជាមរតកឡើយ តែឯផលផ្លែនៃព្រះវិញ្ញាណវិញ នោះគឺសេចក្តីស្រលាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាពសប្បុរស ស្មោះត្រង់ ស្លូតបូត ហើយដឹងខ្នាត គ្មានក្រិត្យវិន័យណា ទាស់នឹងសេចក្តីយ៉ាងនោះទេ

ហើយអស់អ្នកដែលជារបស់ផងព្រះគ្រីស្ទ នោះបានឆ្កាងសាច់ឈាមហើយ ព្រមទាំងសេចក្តីរំជួល នឹងសេចក្តីប៉ងប្រាថ្នាទាំងប៉ុន្មានផង ។

**សំណួរ :**

១. ពេលលោកប៉ុលប្រកាសដំណឹងល្អ តើគាត់បានប្រាប់ប្រជាជនឱ្យធ្វើអ្វី ?

២. ហេតុអ្វីបានជាអ្នកទាំងឡាយណាដែលមានការកែប្រែចិត្តមានការប្រែប្រួលក្នុងជីវិត ?

៣. តើមានអ្វីកើតឡើងនៅពេលពួកអ្នកនៅក្នុងក្រុងអេភេសូរជឿលើព្រះគ្រីស្ទ ?

៤. ហេតុអ្វីបានជាពួកអ្នកជឿនៅក្នុងទីក្រុងអេភេសូរ មិនបន្តថ្វាយបង្គំព្រះចាស់របស់ពួកគេ ?

៥. តើអ្វីជាទីបន្ទាល់នៃពួកអ្នកជឿនៅក្រុងថែស្សាឡូនីច ទាក់ទងទៅនឹងផ្លូវចាស់របស់ពួកគេ ?

៦. ក្រោយពីពួកអ្នកជឿនៅទីក្រុងថែស្សាឡូនីចបានត្រឡប់ទៅរកព្រះវិញ តើពួកគេបានធ្វើអ្វីខ្លះ ?

៧. យោងតាមកាឡាទី ៥:១៩-២៤ តើបទគម្ពីរនេះពិពណ៌នាប្រាប់អ្នកយ៉ាងដូចម្តេចខ្លះ ចំពោះការប្រព្រឹត្តរបស់អ្នកដែលមិនទាន់កែប្រែចិត្ត ?

៨. យោងតាមជំពូកដដែលខាងលើ តើបទគម្ពីរនេះពិពណ៌នាប្រាប់យ៉ាងដូចម្តេចខ្លះ ចំពោះការប្រព្រឹត្តរបស់អ្នកដែលបានកែប្រែចិត្តរួចហើយ ?

# មេរៀនទី៤——សេចក្ដីបៀតបៀន

បន្ទាប់ពីមនុស្សម្នាក់ជឿលើព្រះយេស៊ូវជាព្រះអង្គសង្គ្រោះដោយពិតប្រាកដ ហើយប្រែចិត្តពីអំពើបាបរបស់ពួកគេ នោះនៅគ្រាណាមួយ ពួកគេនឹងចាប់ផ្ដើមជួបប្រទះសេចក្ដីបៀតបៀន ។ សេចក្ដីបៀតបៀននេះគឺមិនមែនគ្រាន់តែកើតចេញពីពាក្យសំដីប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងករណីខ្លះ សេចក្ដីបៀតបៀនអាចកើតចេញពីប្រភពរផ្សេងៗទៀត ដូចជាសេចក្ដីច្រណែនតាមរយៈក្រុមគ្រួសាររបស់ពួកគេ ឬមិត្តភក្តិរបស់ពួកគេ ។ នៅក្នុងមេរៀននេះ យើងនឹងដឹងថា សេចក្ដីបៀតបៀន គឺជាបទពិសោធន៍ធម្មតាសម្រាប់ពួកគ្រីស្ទាន ។

ចូរយើងក្រឡេកមើលប្រវត្តិ និងទីបន្ទាល់របស់សាវ័កប៉ុល ពេលគាត់នៅពីមុខព្រះរាជាអ័គ្រីប៉ា ។ ចូរយើងអានសេចក្ដីប្រកាសដែលគាត់បានប្រាប់នៅចំពោះប្រជាជនម្ដងទៀត ។

<u>សូមអាន កិច្ចការ ២៦:១៩-២០</u>

ដូច្នេះ បពិត្រព្រះរាជាអ័គ្រីប៉ាអើយ ទូលបង្គំមិនបានចចេសនឹងការជាក់ស្ដែងពីស្ថានសួគ៌នោះទេ គឺទូលបង្គំបានប្រាប់ឱ្យមនុស្សទាំងអស់ប្រែចិត្ត ហើយងាកបែរមកឯព្រះវិញ ទាំងប្រព្រឹត្តបែបសំណុំនឹងការប្រែចិត្តផង គឺប្រាប់ដល់ពួកអ្នកដែលនៅក្រុងដាម៉ាសជាមុនដំបូង រួចនៅក្រុងយេរូសាឡិម និងគ្រប់ក្នុងខេត្តយូដា ហើយដល់អស់ទាំងសាសន៍ដទៃផង ។

តើអ្នកគិតថា មានរឿងអ្វីបានកើតឡើងចំពោះសាវ័កប៉ុល នៅពេលដែលគាត់បានប្រកាសប្រាប់ពីដំណឹងល្អនេះយ៉ាងក្លាហាន ? តើអ្នកគិតថា ប្រជាជនចូលចិត្តការបង្រៀននេះឬទេ ពេលដែលពួកគេឮថាពួកគេមានអំពើបាបប្រឆាំងនឹងព្រះពិតតែមួយ ហើយពួកគេត្រូវការប្រែចិត្ត ងាកបែរចេញពីសេចក្ដីងងឹតទៅឯសេចក្ដីពិតវិញនោះ ? តើអ្នកមានអារម្មណ៍ដូចម្ដេច នៅពេលដែលអ្នកបានឮថា មានព្រះពិតតែមួយប៉ុណ្ណោះ ហើយជាព្រះដែលមានព្រះជន្មរស់ ? តើវាពិបាកទេ បើអ្នកគិតថា ផ្លូវចាស់របស់អ្នក គឺជាផ្លូវខុស ? ដោយសារតែក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នកបានជឿ និងដើរតាមផ្លូវចាស់ ព្រមទាំងបានប្រព្រឹត្តអស់ជាច្រើនឆ្នាំនោះ តើវាពិបាកទេ ដើម្បីជឿថា ជំនឿចាស់នោះ វាមិនពិត ? ឥឡូវនេះ សូមអានពីអ្វីដែលបានកើតឡើងចំពោះសាវ័កប៉ុល នៅពេលគាត់បានប្រកាសពីការប្រែចិត្តនេះ។

សូមអាន កិច្ចការ ២៦:២១

ដោយហេតុនោះបានជាពួកសាសន៍យូដាចាប់ទូលបង្គំនៅក្នុងព្រះវិហារ ហើយព្យាយាមនឹងសំលាប់ទូលបង្គំចោល ។

មនុស្សខ្លះបានស្អប់លោកប៉ុល ហើយខ្លះទៀតព្យាយាមសម្លាប់គាត់ ។ ហេតុនេះហើយទើបគាត់ធ្វើទីបន្ទាល់របស់គាត់ពីមុខព្រះរាជាអ័គ្រីប៉ា ។ ហេតុអ្វីបានជាពួកគេស្អប់គាត់ខ្លាំងម្ល៉េះ ? ពួកគេស្អប់ការអធិប្បាយរបស់គាត់ ។ ពួកគេមិនបានជឿលើព្រះបន្ទូលនៃព្រះទេ ។ អ្នកដែលជឿលើព្រះបន្ទូលរបស់ព្រះទាំងអស់ ហើយជឿតាមសេចក្តីសន្យានៃទ្រង់ ចាប់តាំងពីការចាប់ផ្តើមនៃពិភពលោក បានត្រូវគេធ្វើទុក្ខបុកម្នេញ ។ ពួកហោរារបស់ព្រះជាច្រើនត្រូវបានសម្លាប់ ។ ពួកគ្រីស្ទាននៅជុំវិញពិភពលោក សូម្បីតែនៅសព្វថ្ងៃនេះក៏ដោយ ក៏ត្រូវបានគេវាយដំ ឃុំឃាំង ឬ ដាក់ទណ្ឌកម្មផងដែរ ។ ពួកគេជាច្រើនបានបាត់បង់ក្រុមគ្រួសារ ការងារ ឬ មិត្តភក្តិជាដើម ទាំងអស់នេះ គឺព្រោះតែពួកគេជឿ និងគោរពតាមព្រះយេស៊ូវ ។

ព្រះគម្ពីរបរិសុទ្ធប្រាប់យើងថា អស់អ្នកដែលជឿលើព្រះយេស៊ូវ ហើយគោរពតាមព្រះបន្ទូលរបស់ទ្រង់ នឹងទទួលរងនូវសេចក្តីបៀតបៀន ។

សូមអាន ធីម៉ូថេទី២ ៣:១២

អស់អ្នកណាដែលចង់រស់ ដោយគោរពប្រតិបត្តិដល់ព្រះគ្រីស្ទយេស៊ូវ នោះនឹងត្រូវមានសេចក្តីបៀតបៀនដែរ ។

ព្រះយេស៊ូវបានជួបប្រទះនូវសេចក្តីបៀតបៀនយ៉ាងធំ ខណៈពេលដែលទ្រង់បានគង់នៅលើផែនដីនេះ ។ មនុស្សជាច្រើនបានស្អប់ព្រះយេស៊ូវ ព្រោះតែទ្រង់បានប្រកាសថា ទ្រង់គឺជាព្រះអង្គសង្គ្រោះ។ ព្រះយេស៊ូវបានមានបន្ទូលថា ទ្រង់គឺជាព្រះរាជបុត្រានៃព្រះ ដែលបានយាងមកពីឋានសួគ៌ ។ ពួកគេក៏បានស្អប់ទ្រង់ដែរ ព្រោះតែការអធិប្បាយរបស់ទ្រង់ ។ ព្រះយេស៊ូវបានមានបន្ទូលថា ទ្រង់អាចអភ័យទោសឱ្យអំពើបាប ហើយផ្តល់នូវជីវិតដ៏អស់កល្បជានិច្ចឱ្យបាន ។ ទ្រង់បានប្រាប់ដល់ប្រជាជនថា ពួកគេមិនអាចសង្គ្រោះខ្លួនឯងបានទេ បើពួកគេធ្វើតាមផ្លូវសាសនា ឬ ដោយការធ្វើទង្វើល្អនោះ។ ពួកគេបានស្អប់ការបង្រៀនរបស់ទ្រង់ ហើយព្យាយាមបំផ្លាញទ្រង់ ។ នេះហើយជាមូលហេតុដែលអ្នកដឹកនាំសាសនាបានសម្លាប់ទ្រង់ ។ នៅពេលដែលពួកគេបានសម្លាប់ទ្រង់ ពួកគេមិនបានដឹងថា ព្រះយេស៊ូវអនុញ្ញាតឱ្យពួកគេសម្លាប់ទ្រង់ ប្រយោជន៍ឱ្យទ្រង់អាចសងថ្លៃលោះបាបរបស់យើងនោះឡើយ ។ ពួកគេមិនបានដឹងថា បន្ទាប់ពីការសុគត និងការរស់ឡើងវិញរបស់ទ្រង់ នឹងមានមនុស្សរាប់លាននាក់ជឿ ហើយធ្វើតាមទ្រង់នោះដែរ ។

ព្រះយេស៊ូវជាគំរូរបស់យើង ទ្រង់បានបង្រៀនគោលការណ៍អំពីការលះបង់ ដើម្បីភាពជាសិស្សដ៏ពិតប្រាកដ និងសេចក្តីអំណរ ដើម្បីភាពជាសិស្សដ៏ពិតប្រាកដ ។ ឥឡូវនេះ ចូរយើងមើលចំនុចទាំង២នេះ ដែលទាក់ទងនឹងការបង្រៀនរបស់ព្រះយេស៊ូវ ។

# ១. ការលះបង់ ដើម្បីភាពជាសិស្សដ៏ពិតប្រាកដ

ព្រះយេស៊ូវបានព្រមានហ្វូងមនុស្សថា មនុស្សទាំងឡាយណាដែលចង់ធ្វើជាសិស្សរបស់ទ្រង់ ត្រូវតែចេះលះបង់ជាមុនសិន ។

<u>សូមអាន លូកា ១៤:២៥-២៧</u>

មានមនុស្សសន្ធឹកណាស់ ដើរទៅជាមួយនឹងទ្រង់ នោះទ្រង់បែរទៅមានបន្ទូលនឹងគេថា បើអ្នកណាមកឯខ្ញុំ ដោយមិនបានលះអាល័យពីឪពុកម្ដាយ ប្រពន្ធកូន បងប្អូនប្រុសស្រី និងជីវិតខ្លួនឯងផង អ្នកនោះនឹងធ្វើជាសិស្សខ្ញុំមិនបានទេ ហើយអ្នកណាដែលមិនផ្ទុកឈើឆ្កាងខ្លួនមកតាមខ្ញុំ នោះក៏ធ្វើជាសិស្សខ្ញុំមិនបានដែរ ។

តើខដ៏ចំលែកនេះមានអត្ថន័យយ៉ាងដូចម្ដេច ? តើព្រះយេស៊ូវចង់ឱ្យយើងមានអំពើបាប ដោយការស្អប់ឪពុកម្ដាយរបស់យើង និងគ្រួសាររបស់យើងមែនឬទេ ? តើទ្រង់ចង់ឱ្យយើងស្អប់ជីវិតរបស់យើងផ្ទាល់មែនឬទេ ? ព្រះយេស៊ូវកំពុងបង្រៀនយើងអំពីអ្វីមួយ ដែលមានសារៈសំខាន់បំផុត និងអត្ថន័យនៃការដើរតាមទ្រង់ ។ ព្រះយេស៊ូវមិនមែនមានព្រះបន្ទូលថា យើងគួរតែឈប់ស្រលាញ់ក្រុមគ្រួសាររបស់យើង ឬប្រឆាំងនឹងពួកគេទេ ។ ព្រះយេស៊ូវកំពុងតែប្រៀបធៀបសេចក្ដីស្រលាញ់របស់យើងចំពោះទ្រង់ ទៅនឹងសេចក្ដីស្រលាញ់របស់យើងចំពោះមនុស្ស និងវត្ថុដទៃទៀត ។ ព្រះយេស៊ូវជ្រាបថា យើងស្រលាញ់ក្រុមគ្រួសាររបស់យើងខ្លាំងណាស់ ។ យើងស្រលាញ់ជីវិតរបស់យើង ហើយយើងមិនចង់ស្លាប់ទេ ។ ព្រះយេស៊ូវកំពុងតែប្រាប់យើងថា បើយើងចង់ដើរតាមទ្រង់ នោះយើងត្រូវតែស្រលាញ់ទ្រង់ច្រើនជាងអ្វីៗទាំងអស់ សូម្បីតែមនុស្សទាំងឡាយណាដែលយើងស្រលាញ់ជាទីបំផុតក៏ដោយ ។ ហេតុអ្វីបានជាព្រះយេស៊ូវប្រាប់យើងអំពីរឿងនេះ ? នៅពេលដែលយើងដើរតាមទ្រង់ ជួនកាលក្រុមគ្រួសាររបស់យើងអាចនឹងស្អប់យើងក៏មានដែរ ។ កាលដែលយើងដើរតាមព្រះយេស៊ូវ និងការគោរពតាមព្រះបន្ទូលរបស់ទ្រង់ ការនោះអាចធ្វើឱ្យយើងបាត់បង់មិត្តភក្ដិរបស់យើងខ្លះ បាត់បង់ការងារ ឬខាតបង់នៅក្នុងមុខជំនួញរបស់យើងផងដែរ ។ អ្នកខ្លះថែមទាំងបាត់បង់អ្វីៗទាំងអស់ដែលពួកគេមាន សូម្បីតែជីវិតរបស់ពួកគេផងដែរ ។ ការដែលយើងដើរតាមព្រះគ្រីស្ទអាចនាំឱ្យអ្នកដទៃបដិសេធយើង ហើយពេលខ្លះយើងត្រូវប្រឈមមុខនឹងសេចក្ដីស្លាប់ថែមទៀតផង ។ នោះហើយជាអត្ថន័យនៃការយកឈើឆ្កាងមកដាក់នៅលើខ្លួនយើង ។

តើអ្នកដឹងទេថា ឥឡូវនេះ នៅក្នុងប្រទេសវៀតណាម មានពួកគ្រីស្ទានជាច្រើនត្រូវបានចាប់ដាក់គុក ព្រោះតែសេចក្ដីជំនឿរបស់ពួកគេលើព្រះយេស៊ូវ ? ពួកគ្រីស្ទានជាច្រើនបានទទួលទណ្ឌកម្ម ហើយត្រូវបានសម្លាប់នៅក្នុងប្រទេសចិនក្នុងរយៈពេល១០០ឆ្នាំនេះ ។ នៅក្នុងប្រទេសកាន់សាសនាអ៊ីស្លាមខ្លះ មានប្រជាជនខ្លះត្រូវបានសម្លាប់ ហើយក្រុមគ្រួសាររបស់ពួកគេត្រូវបានរងនូវភាពអាម៉ាសមុខ ដោយសារតែសេចក្ដីជំនឿ

របស់ពួកគេលើព្រះយេស៊ូវ ។ ព្រះយេស៊ូវបានមានបន្ទូលប្រាប់ឱ្យយើងដឹងថា រឿងនេះនឹងកើតមានឡើង ហើយទ្រង់បានរំលឹកដល់យើងឱ្យពិចារណាអំពីការលះបង់ មុនពេលក្លាយជាសិស្សរបស់ទ្រង់ ។ តើយើងនឹងស្រលាញ់អ្នកណាច្រើនជាងរវាងព្រះយេស៊ូវ និងមនុស្សដទៃទៀត ?

ព្រះយេស៊ូវបានប្រទាននូវឧទាហរណ៍ពីរ ដើម្បីជួយយើងឱ្យយល់អំពីសារៈសំខាន់នៃរឿងនេះ ។

<u>សូមអាន លូកា ១៤:២៨-៣៣</u>

ដ្បិតក្នុងពួកអ្នករាល់គ្នា បើមានអ្នកណាចង់សង់ផ្ទះពីថ្ម តើមិនអង្គុយលៃលកមើលជាមុនទេឬអី ដើម្បីឱ្យដឹងជាមានល្មមនឹងធ្វើបង្ហើយបានឬមិនបាន ក្រែងកាលណាដាក់ជើងជញ្ជាំង រួចបង្ហើយមិនបាន នោះអស់អ្នកណាដែលឃើញក៏នឹងសើចចំអកឱ្យ ដោយពាក្យថា អ្នកនេះបានចាប់ផ្តើមសង់ផ្ទះ តែបង្ហើយមិនបាន។ ឬតើមានស្តេចឯណា ដែលរៀបចេញទៅច្បាំងនឹងស្តេចមួយទៀត ឥតអង្គុយពិគ្រោះមើលជាមុនសិន ដើម្បីឱ្យដឹងជាខ្លួននាំពលមួយម៉ឺនទៅតទល់នឹងស្តេច ដែលនាំពលពីរម៉ឺន មកច្បាំងបានឬមិនបាន បើឃើញថាមិនបានទេ នោះទ្រង់នឹងចាត់រាជទូត ឱ្យទៅស៊ើបសួរពីកិច្ច ដែលចងស្ពានមេត្រីនឹងគ្នាជាយ៉ាងណា ក្នុងកាលដែលស្តេចនោះនៅឆ្ងាយនៅឡើយ ដូច្នេះ អស់អ្នកណាក្នុងពួកអ្នករាល់គ្នា ដែលមិនលះអាល័យពីរបស់ទ្រព្យខ្លួនទាំងអស់ នោះធ្វើជាសិស្សខ្ញុំមិនបានទេ ។

សូមគិតពិចារណាពីឧទាហរណ៍ពីរ ដែលព្រះយេស៊ូវមានបន្ទូលនៅក្នុងខ២៨-៣៣នេះមើល ហើយថាហេតុអ្វីបានជាព្រះយេស៊ូវទ្រង់លើកយកឧទាហរណ៍ទាំងពីរនេះមកមានបន្ទូលនៅបន្ទាប់ពីខ២៥-២៧ ។

ផ្លូវរបស់ព្រះយេស៊ូវគឺត្រង់ ហើយចង្អៀត ។ មនុស្សជាច្រើននឹងជ្រើសរើសស្រលាញ់យកជីវិតទ្រព្យសម្បត្តិរបស់ពួកគេ ឬមនុស្សដទៃទៀតច្រើនជាងព្រះយេស៊ូវ ។ មនុស្សជាច្រើននឹងជ្រើសរើសយកវត្ថុខាងលើនេះ ហើយគិតថា វាសំខាន់ជាងសេចក្តីសង្គ្រោះ និងជីវិតដ៏នៅអស់កល្បជានិច្ចនៅក្នុងព្រះយេស៊ូវគ្រីស្ទ ។ មនុស្សជាច្រើននឹងមិនយល់អំពីអ្នក ហើយមិនយល់ពីមូលហេតុដែលជីវិតរបស់អ្នកមានការផ្លាស់ប្តូរយ៉ាងខ្លាំងដូច្នេះឡើយ ។ ពួកគេមិនយល់ពីសេចក្តីជំនឿរបស់យើង ហើយមិនយល់ពីមូលហេតុដែលមានសារៈសំខាន់សម្រាប់យើងនោះទេ ។ ចំណុចនេះ វាអាចធ្វើឱ្យអ្នកមិនជឿអាក់អន់ចិត្តដល់អ្នកជឿ ។ សិស្សម្នាក់ក្នុងចំណោមសិស្សរបស់ព្រះយេស៊ូវ គឺសាវ័កពេត្រុសបានពន្យល់ពីមូលហេតុដែលអ្នកជឿធ្វើឱ្យពួកគេអាក់អន់ចិត្ត ។

<u>សូមអាន ពេត្រុសទី១ ៤:១-៤</u>

ដូច្នេះ ដែលព្រះគ្រីស្ទទ្រង់បានរងទុក្ខក្នុងសាច់ឈាមជំនួសយើងរួចហើយ នោះត្រូវឱ្យអ្នករាល់គ្នាមានគំនិតដូច្នោះដែរ ទុកជាគ្រឿងការពារខ្លួន ដ្បិតអ្នកណាដែលបានរងទុក្ខក្នុងសាច់ឈាម នោះបានឈប់ខាងឯអំពើបាបហើយ ដើម្បីកុំឱ្យបង់ពេលដែលសល់ នឹងរស់នៅខាងសាច់ឈាម តាមតែសេចក្តីប៉ងប្រាថ្នា

របស់មនុស្សទៀតឡើយ គឺតាមបំណងព្រះហឫទ័យនៃព្រះវិញ ដ្បិតដែលពីដើម យើងរាល់គ្នាបានធ្វើតាម បំណងចិត្តរបស់សាសន៍ដទៃ ទាំងដើរក្នុងសេចក្តីអាសអាភាស ការស្រើបស្រាល ការចំណូលស្រា ស៊ីផឹកជ្រុល ការប្រមឹក នឹងការថ្វាយបង្គំរូបព្រះ ដែលសុទ្ធតែខុសច្បាប់ នោះល្មមដល់យើងហើយ គេក៏ឆ្ងល់ ដែលអ្នករាល់គ្នា មិនរត់ទៅតាមសេចក្តីខូចអាក្រក់ដ៏ហូរហៀរ ជាមួយនឹងគេដែរ បានជាគេប្រមាថដល់អ្នករាល់គ្នា ។

មនុស្សជាច្រើននឹងចំអកចំអន់ឱ្យយើង ព្រោះតែយើងមិនព្រមធ្វើតាមទម្លាប់នៃអំពើបាបរបស់ពួកគេ ។ យើងនឹងត្រូវបានបៀតបៀន ព្រោះតែដើរតាមព្រះយេស៊ូវ ។ អ្នកទាំងឡាយណាដែលត្រូវបានបៀតបៀន ហើយនៅតែដើរតាមព្រះ នឹងទទួលបាននូវរង្វាន់ជារៀងរហូត គឺការរស់នៅឯឋានសួគ៌ និងព្រះពរជាច្រើនទៀត ។ កិច្ចការទាំងនេះនឹងដឹកនាំយើងទៅរកការបង្រៀនដ៏សំខាន់ទី២ទៀតរបស់ព្រះយេស៊ូវ ដែលទាក់ទងនឹងការបៀតបៀន ។

# ២. សេចក្តីអំណរ ដើម្បីភាពជាសិស្សដ៏ពិតប្រាកដ

ព្រះយេស៊ូវបានធ្វើការសន្យាដ៏អស្ចារ្យទៅដល់ហ្វូងមនុស្ស គឺដល់អ្នកទាំងឡាយណា ដែលត្រូវបាន បៀតបៀន ដោយសារសេចក្តីជំនឿរបស់ពួកគេចំពោះទ្រង់ ។

<u>សូមអាន ម៉ាថាយ ៥:១០-១២</u>

មានពរហើយ អស់អ្នកដែលត្រូវគេបៀតបៀន ដោយព្រោះសេចក្តីសុចរិត ឥ្បិតនគរស្ថានសួគ៌ជារបស់ផង អ្នកទាំងនោះ  អ្នករាល់គ្នាមានពរ ក្នុងកាលដែលគេជេរ បៀតបៀន ហើយនិយាយបង្កុសគ្រប់ទាំងសេចក្តីអាក្រក់ ពីអ្នករាល់គ្នា ដោយព្រោះខ្ញុំ ចូរមានចិត្តអំណរ ហើយរីករាយជាខ្លាំងចុះ ដ្បិតអ្នករាល់គ្នាមានរង្វាន់ជាធំ នៅឯស្ថានសួគ៌ ពីព្រោះគេក៏បានធ្វើទុក្ខដល់ពួកហោរា ដែលនៅមុនអ្នករាល់គ្នា បែបដូច្នោះដែរ ។

តើខដ៏ចំលែកនេះមានអត្ថន័យយ៉ាងដូចម្តេច ? ជាធម្មតាយើងមិនបានគិតថា ការបៀតបៀនជាអ្វីមួយ ដែលគួរឱ្យរីករាយនោះទេ ។ នៅក្នុងខនេះ ព្រះយេស៊ូវបានសន្យាថា នឹងប្រទានពរដ៏បរិបូណ៌ដល់ មនុស្សទាំងឡាយណាដែលស៊ូទ្រាំក្នុងការបៀតបៀន ព្រោះតែសេចក្តីជំនឿរបស់ពួកគេចំពោះទ្រង់ ។ ហេតុអ្វីបានជាព្រះប្រទានការសន្យានេះដល់ប្រជារាស្ត្ររបស់ទ្រង់ ?  ព្រះបានប្រទានការសន្យានេះទៅដល់ ប្រជារាស្ត្ររបស់ទ្រង់ ដើម្បីជាការលើកទឹកចិត្តពួកគេឱ្យតស៊ូដល់ទីបំផុត ។ យើងត្រូវតែរីករាយនៅក្នុងការរងទុក្ខ របស់យើង ហើយនឹកចាំពីការរងទុក្ខ ដែលព្រះយេស្ទូវបានទទួលរងជំនួសយើង ។

ជាថ្មីម្តងទៀត សាវ័កពេត្រុសបានបង្រៀនយើងអំពីការបៀតបៀន ។

<u>សូមអាន ពេត្រុសទី១ ៤:១២-១៤</u>

ពួកស្ងួនភ្ងាអើយ កុំឱ្យមានប្លែកក្នុងចិត្ត ដោយភ្លើងដ៏ក្តៅក្រហាយ ដែលកំពុងតែល្បងអ្នករាល់គ្នា ទុកដូចជាកើតមានសេចក្តីចំឡែកនោះឡើយ ត្រូវអរសប្បាយវិញ ដោយព្រោះមានចំណែកក្នុងការរងទុក្ខរបស់ព្រះគ្រីស្ទ ដើម្បីឱ្យអ្នករាល់គ្នាបានត្រេកអររីករាយជាខ្លាំង ក្នុងកាលដែលសិរីល្អទ្រង់លេចមក បើសិនជាគេតិះដៀលអ្នករាល់គ្នា ដោយព្រោះព្រះគ្រីស្ទ នោះមានពរហើយ ពីព្រោះព្រះវិញ្ញាណដ៏មានសិរីល្អ គឺជាព្រះវិញ្ញាណនៃព្រះទ្រង់សណ្ឋិតលើអ្នករាល់គ្នាហើយ ។

យើងនឹងទទួលបានព្រះពរ នៅពេលដែលយើងបានទទួលនូវការបៀតបៀនដោយសារតែការជឿលើព្រះគ្រីស្ទ ។ យើងគួរតែមានចិត្តរីករាយ នៅពេលដែលមានការបៀតបៀននោះ ព្រោះការនេះបានបញ្ជាក់ប្រាប់យើងថា ព្រះវិញ្ញាណបរិសុទ្ធសណ្ឋិតនៅក្នុងយើង ។ នៅក្នុងគ្រាដែលមានការបៀតបៀនទាំងនេះ យើងត្រូវតែទុកចិត្តលើសេចក្តីស្មោះត្រង់របស់ព្រះ ហើយជឿជាក់លើការសន្យារបស់ទ្រង់ថា ទ្រង់នឹងផ្តល់សេចក្តីយុត្តិធម៌នៅថ្ងៃជំនុំជំរះ ។ ដូច្នេះ យើងត្រូវតែទុកចិត្តលើព្រះ ។

សូមអាន ពេត្រុសទី១ ៤:១៩

ដូច្នេះ ពួកអ្នកដែលរងទុក្ខ តាមព្រះហឫទ័យនៃព្រះ នោះត្រូវផ្ញើព្រលឹងខ្លួន ទុកនឹងព្រះដ៏បង្កបង្កើត ដែលទ្រង់ស្មោះត្រង់ ដោយខ្លួនប្រព្រឹត្តការល្អចុះ ។

សំណួរ :

១. ពេលដែលសាវ័កប៉ុលអធិប្បាយបង្រៀនដល់សាសន៍យូដាជាច្រើន តើគាត់ទទួលបានការឆ្លើយតបបែបណាពីពួកគេ ?

២. ហេតុអ្វីបានជាពួកគេតាមរកសំឡាប់គាត់ នៅពេលដែលគាត់អធិប្បាយនោះ ?

៣. តើពួកគ្រីស្ទានទាំងអស់ប្រឈមមុខនឹងការបៀតបៀនដែរឬទេ ?

៤. យោងតាម លូកា ១៤:២៥-២៧ តើព្រះយេស៊ូវបានបង្រៀនយើងអំពីអ្វីខ្លះ ដែលយើងត្រូវតែធ្វើ បើយើងនឹងជឿទៅលើទ្រង់ ហើយធ្វើតាមទ្រង់ ?

៥. តើការលះអាល័យពីឪពុកម្តាយ បងប្អូនប្រុសស្រី ប្រពន្ធ និងកូនចៅ ដើម្បីដើរតាមព្រះយេស៊ូវ មានអត្ថន័យយ៉ាងដូចម្តេច ?

៦. តើការលីឈើឆ្កាងរបស់អ្នកមានអត្ថន័យយ៉ាងដូចម្តេច ?

៧. យោងតាម លូកា ១៤:២៨-៣៣ តើតាមរយៈឧទាហរណ៍ទាំងពីរ ដែលព្រះយេស៊ូវបានប្រទានឱ្យយើងដឹងពីសារៈសំខាន់នៃការសំរេចចិត្តធ្វើតាមទ្រង់ មានអ្វីខ្លះ ?

៨. ហេតុអ្វីបានជាពួកអ្នកដែលមិនជឿ សើចចំអកឱ្យយើងនៅពេលយើងផ្លាស់ប្រែចិត្ត ហើយដើរតាមព្រះយេស៊ូវ ?

៩.	យោងតាម ម៉ាថាយ ៥:១០-១២ តើពួកគ្រីស្ទានគួរតែមានឥរិយាបថបែបណាចំពោះការបៀតបៀន ?

១០.	យោងតាម ពេត្រុសទី១ ៤:១២-១៤ តើការបៀតបៀនបញ្ជាក់ពីអ្វីចំពោះព្រះវិញ្ញាណបរិសុទ្ធ ?

១១.	យោងតាម ពេត្រុសទី១ ៤:១៩ តើអ្នកជឿម្នាក់ត្រូវធ្វើអ្វីខ្លះ នៅពេលដែលមានការបៀតបៀន ?

# មេរៀនទី៥——ពិធីជ្រមុជទឹក

យើងបានសិក្សាពីមូលដ្ឋានគ្រឹះនៃសេចក្ដីជំនឿនៅក្នុងមេរៀនទី១ និងទី២ ហើយនិងការផ្លាស់ប្រែចិត្ត នៅក្នុងមេរៀនទី៣ និងទី៤ហើយ ។ ឥឡូវនេះ យើងនឹងរៀនពីការមួយទៀត ដែលមានសារៈសំខាន់ខ្លាំងណាស់ សំរាប់ពួកគ្រីស្ទានទាំងអស់ នោះគឺជាពិធីជ្រមុជទឹក ។ នៅពេលដែលយើងមើលព្រះបន្ទូលនៃព្រះយេស៊ូវ យើងឃើញថា ពួកអ្នកជឿលើព្រះយេស៊ូវនៅជំនាន់មុន ពួកគេសុទ្ធតែទទួលពិធីជ្រមុជទឹកនៅក្នុងទន្លេទាំងអស់ ។ តើអ្វីជាពិធីជ្រមុជទឹក ? ហេតុអ្វីយើងត្រូវទទួលពិធីជ្រមុជទឹក ? តើនរណាខ្លះដែលត្រូវទទួលពិធីជ្រមុជទឹក ? យើងនឹងឆ្លើយសំណួរទាំងអស់នេះដូចខាងក្រោម ។

## ១.	បទបញ្ញត្តនៃពិធីជ្រមុជទឹក

មុនពេលព្រះយេស៊ូវយាងទៅកាន់ឋានសួគ៌វិញ ទ្រង់បានប្រទានបទបញ្ញត្តដ៏សំខាន់មួយ ទៅកាន់ពួកសិស្សរបស់ព្រះអង្គ ។

<u>សូមអាន ម៉ាថាយ ២៨:១៩</u>

ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឱ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឱ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ ។

អស់អ្នកដែលជឿ ហើយក្លាយជាសិស្សរបស់ព្រះយេស៊ូវ នោះត្រូវតែទទួលពិធីជ្រមុជទឹក ។ ពិធីជ្រមុជទឹក មានសារៈសំខាន់ណាស់ចំពោះព្រះ និងជាជំហានដំបូងនៃការប្រតិបត្តិរបស់គ្រីស្ទានថ្មី ។ ពិធីជ្រមុជទឹក គឺសំរាប់តែអ្នកណា ដែលសំរេចចិត្តធ្វើជាសិស្សពិតប្រាកដរបស់ព្រះយេស៊ូវគ្រីស្ទតែប៉ុណ្ណោះ ។

## ២.	អត្ថន័យនៃពិធីជ្រមុជទឹក

តើអត្ថន័យនៃពិធីជ្រមុជទឹកគឺជាអ្វី ? តើពិធីជ្រមុជទឹកមានអ្វីខ្លះ ? <u>ពិធីជ្រមុជទឹកមិនមែនជា</u> :

១.	វិធីដើម្បីទទួលបានផលបុណ្យកុសលអ្វីនោះទេ ។ ព្រះយេស៊ូវបានធ្វើបុណ្យទាំងអស់ សំរាប់យើងតាមរយៈជីវិតរស់នៅ និងការសុគតរបស់ទ្រង់រួចហើយ ។

២.	ពិធីសាសនាដែលយើងធ្វើ ដើម្បីទទួលសំណាងល្អសំរាប់ក្រុមគ្រួសារ ឬមុខជំនួញរបស់យើងនោះទេ ។

៣.	វិធីដើម្បីសំអាតអំពើបាបរបស់យើងទេ ។ គឺមានតែព្រះលោហិតនៃព្រះយេស៊ូវប៉ុណ្ណោះ ដែលមានព្រះចេស្តាសំអាតអំពើបាបរបស់យើងបាន ។

៤.	ផ្នែកសំខាន់អ្វីមួយនៃសេចក្តីសង្គ្រោះ ដែលនាំឱ្យយើងរួចពីអំពើបាបនោះទេ ។ សេចក្តីសង្គ្រោះគឺជាអំណោយទាននៃព្រះ ដែលមកពីការសងថ្លៃលោះបាបនៅលើឈើឆ្កាង របស់ព្រះយេស៊ូវ ។ យើងទទួលសេចក្តីសង្គ្រោះដោយសារព្រះគុណតាមរយៈសេចក្តីជំនឿ គឺមិនមែនអាងលើការប្រព្រឹត្តល្អរបស់យើងនោះឡើយ ។

<u>សូមអាន អេភេសូរ ២:៨-៩</u>

ត្បិតគឺព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្តីជំនឿ ហើយសេចក្តីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តដែរ ក្រែងអ្នកណាអួតខ្លួន ។

បើពិធីជ្រមុជទឹកមិនមែនជាអ្វីៗដែលបានរៀបរាប់នៅខាងលើនេះទេ ដូច្នេះ តើពិធីជ្រមុជទឹកគឺជាអ្វី ?

<u>ពិធីជ្រមុជទឹកគឺជា</u> :

## ក.	ទីបន្ទាល់នៃសេចក្តីសង្គ្រោះក្នុងព្រះគ្រីស្ទ

យើងទទួលពិធីជ្រមុជទឹក ដើម្បីបង្ហាញអ្នកដែលបានជឿរួចហើយថា យើងបញ្ជាក់សេចក្តីជំនឿរបស់យើងក្នុងព្រះយេស៊ូវ ហើយយើងចង់ធ្វើឱ្យដូចពួកគេដែរ ។ម្យ៉ាងទៀត ដើម្បីបង្ហាញអ្នកមិនទាន់ជឿថា យើងបានចាកចេញពីផ្លូវចាស់របស់យើង ដើម្បីដើរតាមព្រះយេស៊ូវ ។

## ខ.	ទីសំគាល់នៃអ្វីៗដែលបានកើតឡើងចំពោះយើងខាងឯវិញ្ញាណ

នៅពេលយើងទទួលពិធីជ្រមុជទឹក មានទីសំគាល់បីយ៉ាង ដែលបញ្ជាក់ពីការកើតឡើងចំពោះអ្នកជឿខាងឯវិញ្ញាណគឺ :

១,	ពេលយើងឈរនៅក្នុងទឹក នោះប្រៀបដូចជា យើងបានរស់ក្នុងជីវិតចាស់ និងផ្លូវចាស់របស់យើង ។

២.	ពេលយើងជ្រមុជនៅក្នុងទឹក នោះប្រៀបដូចជា យើងត្រូវបានស្លាប់ខាងជីវិតចាស់ និងផ្លូវចាស់របស់យើង ។

៣.	ពេលយើងងើបពីទឹកវិញ នោះប្រៀបដូចជា យើងត្រូវបានរស់ឡើងវិញជាមួយព្រះយេស៊ូវ ដោយព្រះបានប្រទានឱ្យយើងបានជីវិតថ្មីក្នុងព្រះយេស៊ូវគ្រីស្ទ ។

## គ.	ការសំរេចចិត្តចូលជាសមាជិកនៅក្នុងក្រុមជំនុំ

នៅពេលយើងទទួលពិធីជ្រមុជទឹករួច យើងនឹងក្លាយជាសមាជិកនៅក្នុងក្រុមជំនុំ ។ ពិធីនេះសំខាន់ខ្លាំងណាស់ចំពោះតែអ្នកដែលមានសេចក្តីជំនឿពិត ហើយកែប្រែចិត្តតែប៉ុណ្ណោះ ។ សូមមើលពីអ្វីដែលព្រះគម្ពីរបានសរសេរអំពីប្រជាជន៣០០០នាក់ ដែលបានជឿលើព្រះគ្រីស្ទ ក្នុងពេលតែមួយថ្ងៃ ។

<u>សូមអាន កិច្ចការ ២:៤១</u>

នោះពួកអ្នកដែលទទួលពាក្យគាត់ដោយអំណរម ក៏បានទទួលបុណ្យជ្រមុជទឹក ហើយនៅថ្ងៃដដែលនោះ មានប្រហែលជា៣០០០នាក់ថែមកើនឡើងទៀត ។

ពិធីជ្រមុជទឹកមានសារៈសំខាន់ខ្លាំងណាស់ ។ បើមនុស្សម្នាក់អះអាងថា ខ្លួនជឿលើព្រះគ្រីស្ទ ប៉ុន្តែបែរជាមិនចង់ទទួលពិធីជ្រមុជទឹក ដោយគាត់ខ្លាចប្រតិកម្មរបស់អ្នកដទៃចំពោះគាត់នោះ គឺអ្នកនោះកំពុងតែបង្ហាញខ្លួនថា ខ្លួនមិនទាន់មានសេចក្តីជំនឿពិតប្រាកដលើព្រះយេស៊ូវគ្រីស្ទនៅឡើយទេ ។

<u>សំណួរ :</u>

១.	តើនរណាបានបង្គាប់ឱ្យអ្នកជឿទាំងអស់ទទួលពិធីជ្រមុជទឹក ?

២.	តើចំនុចអ្វីខ្លះ ដែលផ្ទុយពីអត្ថន័យនៃពិធីជ្រមុជទឹក ?

៣.	តើអត្ថន័យនៃពិធីជ្រមុជទឹកមានអ្វីខ្លះ ?

៤.	តើពិធីជ្រមុជទឹកមានទីសំគាល់អ្វីខ្លះ ?

៥.	តើយើងក្លាយទៅជាអ្វី នៅពេលដែលយើងបានទទួលពិធីជ្រមុជទឹករួច ?